ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 13-Jun-2011, 08:34
CMS/CFO: Uch Arun

# នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារនៃការដាក់ឯកសារ

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០៣/០៧-០៩-២០០៩-អវតក/កសចស |
| ដាក់ទៅ | : | សហចៅក្រមស៊ើបអង្កេត |
| ថ្ងៃដាក់ | : | ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១១ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញាអន្តរជាតិ |
| ភាសាដើម | : | **អង់គ្លេស** |

## ចំណាត់ថ្នាក់ឯកសារ

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សម្ងាត់**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយការិ.សហចៅក្រមស៊ើបអង្កេត: សម្ងាត់/Confidential

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

## សំណើបំពេញកិច្ចស៊ើបសួរលើកទីបីរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទិននឹង មាស មុត និងទីតាំងឧក្រិដ្ឋកម្មដែលពាក់ព័ន្ធ

---

| **អ្នកដាក់ឯកសារ:** | **អ្នកទទួលឯកសារ:** | **ចម្លងជូន:** |
|---|---|---|
| សហព្រះរាជអាជ្ញាអន្តរជាតិ: | ការិ.សហចៅក្រមស៊ើបអង្កេត: | សហព្រះរាជអាជ្ញាជាតិ: |
| លោក Andrew CAYLEY | ចៅក្រម យូ ប៊ុនឡេង | លោកស្រី ជា លាង |
| | ចៅក្រម Siegfried BLUNK | |

# ពាក្យសុំឲ្យទទួលស្គាល់ចំពោះសុពលភាពនៃសំណើ សុំឲ្យបំពេញកិច្ចស៊ើបសួរ

១. កាលពីថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១១ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសំរេចរបស់ខ្លួនលើសំណើសុំពន្យាពេលបន្ថែម និងសុំឲ្យបំពេញកិច្ចស៊ើបសួរដែលធ្វើឡើងដោយសព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងសំណុំរឿងលេខ០០៣ ("ដីកាសម្រេច")[1] ដែលតាមដីកាសំរេចនេះ សហចៅក្រមស៊ើបអង្កេតបានបដិសេធនូវសំណើសុំចំនួនបួនដែលបានដាក់ដោយ សហព្រះរាជអាជ្ញាអន្តរជាតិតែម្នាក់ឯង ថាគ្មានសុពលភាព៖ សំណើសុំឲ្យបំពេញកិច្ចស៊ើបសួរចំនួនបីដែលរួមមាន សំណើសុំក្នុងពេលនេះ[2] និងសំណើមួយដែលសុំឲ្យពន្យារពេលកំណត់សំរាប់ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងលេខ០០៣[3] ។ អនុលោមតាមវិធាន៣៩.៤ នៃវិធានផ្ទៃក្នុង និងមាត្រា ៨ និង៩ នៃសេចក្តីណែនាំអនុវត្តក្នុងការដាក់ឯកសារនៅចំពោះមុខ អវតក សហព្រះរាជអាជ្ញាអន្តរជាតិ សូមដាក់ជូនសារជាថ្មីឡើងវិញនូវសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ និងសូមស្នើឲ្យសហចៅក្រមស៊ើបអង្កេតទទួលស្គាល់នូវសុពលភាពនៃសំណើសុំនេះ ថាជាបណ្តឹងដែលកំពុងតែអនុវត្តនៅបន្ទាប់ពីការផុតនៃពេលវេលាកំណត់ ដោយផ្អែកតាមការដែលខ្លួនយល់ឃើញថាជាការសមស្រប។

២. មូលដ្ឋាននៃការការដាក់សំណើនេះសារជាថ្មី នៅក្រោយពេលហួសកំណត់ដែលបានចែងនៅក្នុងវិធាន៦៦.១ នៃវិធានផ្ទៃក្នុង គឺថា សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់នៅក្នុងសេចក្តីសម្រេចស្តីពីការបកស្រាយរបស់ខ្លួនពាក់ព័ន្ធទៅនឹងទម្រង់បែបបទ ដែលចាំបាច់សម្រាប់ឲ្យសហព្រះរាជអាជ្ញាណាមួយដាក់សំណើសុំបែបដូច្នេះ តែម្នាក់ឯង ។ សំណើសុំឲ្យបំពេញកិច្ចស៊ើបសួរនេះត្រូវបានច្រានចោលដោយមានមូលដ្ឋាននៅលើបច្ចេកទេសនៃនីតិវិធីចំនួនពីរ និងមិនត្រូវបានពិចារណាលើអង្គសេចក្តីរបស់វាឡើយ។ សហចៅក្រមស៊ើបអង្កេតបានរកឃើញថា ដើម្បីឲ្យសហព្រះរាជអាជ្ញា

---

[1] ដីកាសម្រេចស្តីពីសំណើសុំពន្យារពេលកំណត់ និងសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ ស្នើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិពាក់ព័ន្ធនឹងសំណុំរឿង០០៣ របស់ កសចស, D20/3, ថ្ងៃទី៧ មិថុនា ២០១១ ("ដីកាសម្រេច") ។

[2] សំណើសុំឲ្យបំពេញកិច្ចស៊ើបសួរលើកទី១ របស់ហព្រះរាជអាជ្ញាអន្តរជាតិ សុំឲ្យទទួលយកឯកសារបន្ថែម និងសេចក្តីសង្កេតលើស្ថានភាពនៃកិច្ចស៊ើបសួរ, ថ្ងៃទី១៨ ឧសភា ២០១១, D17 ។ សំណើលើកទី២ របស់ហព្រះរាជអាជ្ញាអន្តរជាតិ សុំឲ្យបំពេញកិច្ចស៊ើបសួរបន្ថែមពាក់ព័ន្ធនឹងលោក ស៊ូ ម៉េត ព្រមទាំងពាក់ព័ន្ធនឹងទីកន្លែងប្រព្រឹត្តបទល្មើស, ថ្ងៃទី១៨ ឧសភា ២០១១, D18 ។ សំណើសុំបំពេញកិច្ចស៊ើបសួរលើកទី៣ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទិននឹង មាស មុត និងទីតាំងឧក្រិដ្ឋកម្មដែលពាក់ព័ន្ធ, ថ្ងៃទី១៨ ឧសភា ២០១១, D19 ។

[3] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំពន្យារពេលវេលាកំណត់សម្រាប់ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿងលេខ ០០៣ និងសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ ដាក់ដោយ ទាក់ទងនឹងសំណុំរឿងលេខ០០៣, ថ្ងៃទី១០ ឧសភា ២០១១, D15 ។

ណាមួយម្នាក់ចាត់វិធានការតែម្នាក់ឯង គឺវាត្រូវតែមានការផ្ទេរនូវសិទ្ធិអំណាចតាមផ្លូវការ ទៅតាមវិធាន១៣.៣ ឬ ការខ្វែងយោបល់ត្រូវបានចុះបញ្ជី ដោយអនុលោមវិធាន៧១.១ នៃវិធានផ្ទៃក្នុង[4] ។ ខណៈដែលសហព្រះរាជអាជ្ញាអន្តរជាតិកំពុងប្តឹងឧទ្ធរណ៍ ការបកស្រាយរបស់សហចៅក្រមស៊ើបអង្កេត លើវិធានផ្ទៃក្នុងទាក់ទងទៅនឹងការចុះបញ្ជីលើការខ្វែងយោបល់គ្នា សហព្រះរាជអាជ្ញាឥឡូវនេះ បានធ្វើការកត់ត្រានូវចរិតលក្ខណៈចំៗនៃការខ្វែងយោបល់របស់ពួកខ្លួន ដែលទាក់ទងទៅនឹងសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ នៅលើឯកសារមួយដែលបានចុះហត្ថលេខា និងចុះកាលបរិច្ឆេទនៅថ្ងៃនេះ ហើយបានដាក់វាចូលទៅក្នុងបញ្ជីខ្វែងយោបល់គ្នាមួយ ដែលត្រូវបានរក្សាទុកដោយក្រឡាបញ្ជីរបស់សហព្រះរាជអាជ្ញា ។

៣. ដោយសារសំណុំបែបបទមួយក្នុងចំណោមសំណុំបែបបទនានា ដែលចាត់ទុកថាចាំបាច់ត្រូវធ្វើតាមរយៈសេចក្តីសំរេចឥឡូវនេះត្រូវបានបំពេញសព្វគ្រប់ ហើយមិនមានធ្វើឲ្យខូចដល់បណ្តឹងឧទ្ធរណ៍ដែលត្រូវដាក់ដោយ សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងបញ្ហានេះ សហព្រះរាជអាជ្ញា សូមស្នើដល់សហចៅក្រមស៊ើបអង្កេតមេត្តាទទួលស្គាល់ថា សំណើសុំឲ្យបំពេញកិច្ចស៊ើបសួរនេះមានសុពលភាព ហើយឥឡូវនេះសូមឲ្យមេត្តាធ្វើការពិនិត្យលើអង្គសេចក្តី។ ការអនុវត្តនូវឆន្ទានុសិទ្ធិតាមរបៀបនេះនឹងធានាឲ្យប្រាកដថា បច្ចេកទេសក្នុងការគ្រប់គ្រងផ្នែកច្បាប់ គឺមិនជាឧបសគ្គរាំងដល់ភាពត្រឹមត្រូវ ភាពប្រាកដប្រជានៃច្បាប់ និងតម្លាភាពនៃដំណើរការនីតិវិធីអនុលោមតាមវិធាន២១.១ នៃវិធានផ្ទៃក្នុង ហើយនឹងសិទ្ធិជាមូលដ្ឋានរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ ក្នុងការធ្វើសំណើសុំឲ្យបំពេញកិច្ច ស៊ើបសួរជាបន្ថែមទៀត នៅពេលធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចស៊ើបសួរ អនុលោមតាមវិធាន៦៦.១ នៃវិធានផ្ទៃក្នុង។

## សេចក្តីផ្តើម

៤. អនុលោមតាមវិធាន៦៦(១) នៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញាអន្តរជាតិសូមដាក់ជូនសហចៅក្រម (ស.ច.ស) នូវសំណើបំពេញកិច្ចស៊ើបសួរលើកទីបីនេះ ទាក់ទិននឹង មាស មុត និងទីតាំងឧក្រិដ្ឋកម្មដែលពាក់ព័ន្ធ (“សំណើ”) ។ សំណើនេះ ទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្ម/ការចោទប្រកាន់ព្រហ្មទណ្ឌនានាដូចជា: មន្ទីរសន្តិសុខ វត្តឥន្ទញាណ, ការដ្ឋានវាយថ្មស្ទឹងហាវ និងទីតាំងដែលពាក់ព័ន្ធ, ការចាប់ជនជាតិបរទេស ដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ, ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងប្រទេសវៀតណាម និងសិទ្ធិអំណាច និងការចូលរួមពាក់ព័ន្ធរបស់ មាស មុត នៅក្នុងឧក្រិដ្ឋកម្ម

[4] ដីកាសម្រេច, កថាខណ្ឌទី ៥ ។

ទាំងនេះ ។ សំណើនេះ ទាយចំណាប់អារម្មណ៍ទៅនឹងផ្នែកនានានៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដែលចាំបាច់តម្រូវឲ្យមានកិច្ចស៊ើបសួរដ៏សំខាន់បន្ថែមទៀត និងចង្អុលបង្ហាញនូវជំហ៊ានជាក់លាក់នានាសម្រាប់កិច្ចស៊ើបសួរដែលត្រូវចាត់ធ្វើឡើងដោយ ស.ច.ស ។

៥. សហព្រះរាជអាជ្ញាអន្តរជាតិសន្និដ្ឋានថា កិច្ចស៊ើបសួរមិនទាន់ចប់សព្វគ្រប់ទេ ។ សហព្រះរាជអាជ្ញាអន្តរជាតិលើកយោង និងបង្រួបបង្រួមតាមរយៈសេចក្តីយោងនៃសេចក្តីសង្កេតរបស់ខ្លួនក្នុងកថាខ័ណ្ឌទី៣-១៩ នៃសំណើសុំបំពេញកិច្ចស៊ើបសួរលើកទីមួយ នៅក្នុងករណីនេះ ។ ទីតាំងឧក្រិដ្ឋកម្ម/ការចោទប្រកាន់ព្រហ្មទណ្ឌខាងលើ ត្រូវបានដោះស្រាយវែកញែកដាច់ដោយឡែកនៅខាងក្រោមនេះ ។

## មន្ទីរសន្តិសុខ វត្តឥន្ទញ្ញាណ និង កងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ

៦. កិច្ចស៊ើបសួរមកទល់ពេលនេះ បានបញ្ជាក់អះអាងអំពីអត្ថិភាពនៃមន្ទីរសន្តិសុខ វត្តឥន្ទញ្ញាណ ដែលស្ថិតនៅក្រុងកំពង់សោម និងបានធ្វើប្រតិបត្តិការនៅក្រោមបញ្ជារបស់កងពលធំលេខ១៦៤ (កងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ) ចាប់ពីដើមខែ ឧសភា ឆ្នាំ១៩៧៥ រហូតដល់យ៉ាងហោចណាស់ខែមីនា ឆ្នាំ១៩៧៨[5]។ នៅក្នុងបរិវេណនៃមន្ទីរសន្តិសុខនេះមានអគារសំខាន់ៗចំនួនបីខ្នង ដែលហាក់ដូចជាផ្ទុកនូវអ្នកទោសក្នុងចំនួនមួយដ៏ច្រើន[6] ។ មន្ទីរនេះក៏មានទីតាំងរណ្តៅសពយ៉ាងហោចណាស់មួយ (ចំការក្រូចឆ្មារ) ដែលគេបានរកឃើញសាកសពចំនួន២០០ ។ ភស្តុតាងដែលប្រមូលបានសបញ្ជាក់ឲ្យឃើញថាជនរងគ្រោះបានជាប់ចំណងនៅពេលស្លាប់ និងត្រូវបានសម្លាប់ដោយការប្រើវត្ថុដែលនាំឲ្យមានការប៉ះទង្គិចដ៏ខ្លាំងក្លា[7] ។ ទីតាំងទីពីរ (ចំការធុរ៉េន) ត្រូវបានចង្អុលបង្ហាញថា ជារណ្តៅសពរួម ដែលបានប្រើដោយកងពលធំ១៦៤ និងថាបើដូច្នេះ វាទំនងជាជាប់ទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនេះ[8] ។

៧. ជនរងគ្រោះដែលបានជាប់ក្នុងមន្ទីរឃុំឃាំងនៅ វត្តឥន្ទញ្ញាណ រួមមាន ទ័ពកម្ពុជាប្រជាធិបតេយ្យ ពលរដ្ឋវៀតណាម និងថៃ និងទាហានអាមេរិកកាំង[9] ។ ភស្តុតាងសក្ខីកម្មបង្ហាញឲ្យឃើញថា កង

---

[5] របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង, ២៩ ធ្នូ ២០១០, D2/22, ត្រង់ទំព័រទី៤-៥ ។

[6] ក្នុងឯកសារដដែលដូចខាងលើ, ត្រង់ទំព័រទី៤ (ចំនួនខ្មោះដែលបានរកឃើញសបញ្ជាក់ថា សមត្ថភាពអាចផ្ទុកអ្នកទោសយ៉ាងហោចណាស់ ១០០នាក់) ។

[7] ក្នុងឯកសារដដែលដូចខាងលើ ត្រង់ទំព័រទី៦, ១៨។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូច កុយ, ២៨ កក្កដា ២០១០, D2/4, ទំព័រទី៧។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កសព លើឈ្មោះ បុច កុយ (ប៊ូច កុយ), ១២ សីហា ២០០៨, D1.3.13.1, ទំព័រទី ៣ ។

[8] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូច សឿលី, ១១ វិច្ឆិកា ២០១០, D2/16, ទំព័រទី៦ ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញូង ជ្រោង, ២៤ សីហា ២០១០, D2/6, ទំព័រទី៩-១០ ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ិន សារឿន, ១២ វិច្ឆិកា ២០១០, D2/17 ។

[9] របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង, ២៩ ធ្នូ ២០១០, D2/22, ត្រង់ទំព័រទី៥, ៧ ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កសព លើឈ្មោះ បុច កុយ (ប៊ូច កុយ), ១២ សីហា ២០០៨, D1.3.13.1, ទំព័រទី៣ ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កសព ទូច

វរៈសេចនាតូច៤៥០ ដែលជាអង្គភាពសន្តិសុខពិសេសធ្វើប្រតិបត្តិការនៅក្រោមមន្ទីរនេះ និងបានរាយការណ៍ដោយផ្ទាល់ទៅកងពលធំ១៦៤[10]
បានអនុវត្តការបោសសម្អាតយ៉ាងធំលើកម្មាភិបាលមកពីភូមិភាគបូព៌ា ដែលជាលទ្ធផលមនុស្សជាច្រើនរយនាក់ត្រូវបានចាប់ខ្លួន និងទំនងជាបានមកជាប់គុកនៅមន្ទីរសន្តិសុខ វត្តឥន្ទញាណ[11] នេះ ។ អ្នកស៊ើបអង្កេតរបស់ការិយាល័យ កសចស បានរកឃើញថា សមាជិកនៃកងពលធំ១៦៤ រួមទាំង អ្នកជិះទូកកំសាន្តដែលត្រូវបានសម្លាប់ នៅ ស-២១ បានជាប់គុកនៅ វត្តឥន្ទញាណ[12] ។

៨. គេត្រូវការកិច្ចស៊ើបអង្កេតបន្ថែមដ៏សំខាន់មួយ ទាក់ទិននឹងទីតាំងឧក្រិដ្ឋកម្មនេះ ។ របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ដែលដាក់ចំណងជើងថា “បឋម” សំដៅទៅលើតែការស្តាប់ចម្លើយសាក្សីនៃបុគ្គលពីរនាក់គត់ ហើយសន្និដ្ឋានថា កិច្ចស៊ើបសួរមិនទាន់បញ្ចប់[13] ។ សាក្សីទាំងពីររូបនេះដែលបានស្តាប់ចម្លើយរួចហើយ បានផ្តល់ឈ្មោះសាក្សីសក្តានុពលមួយចំនួនបន្ថែមទៀត ដែលក្នុងចំណោមពួកគាត់មានមួយចំនួននៅរស់នៅឡើយ (សូមមើលខាងលើ)[14] ។ ជាការបន្ថែមឈ្មោះបុគ្គលពីររូបដែលបានផ្តល់ជូនដោយសហព្រះរាជអាជ្ញា មិនបានស្តាប់ចម្លើយពួកគាត់ទេទាក់ទិននឹងទីតាំងនេះ[15] ។

៩. កិច្ចស៊ើបសួរក៏បញ្ជាក់ផងដែរថា ជាការបន្ថែមលើប្រតិបត្តិការទៅលើមន្ទីរសន្តិសុខ វត្តឥន្ទញាណ កងពលធំ១៦៤ បានប្រព្រឹត្តបទឧក្រិដ្ឋនានាប្រឆាំងនឹងជនជាតិបរទេស តាមរយៈការវាយប្រហារ

---

ស៊ូលី (ទូច សឿលី), ១៦ សីហា ២០០៨, D1.3.13.13, ទំព័រទី៧ (បញ្ជាក់ពីវត្តមាននៃខោរ/អាវទ្រនាប់ជាតិនីឡុងនៅលើសំណល់សាកសព ដែលរកឃើញ ដែលជាសម្លៀកបំពាក់តាមបទដ្ឋានយោធាដែលគេបើកឱ្យ) ។

[10] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូច សឿលី, ១០ វិច្ឆិកា ២០១០, D2/15, ទំព័រទី៦ ។

[11] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សយ ប៊ិន, ៩ កញ្ញា ២០១០, D2/10, ទំព័រទី៥ ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូច សឿលី, ១១ វិច្ឆិកា ២០១០, D2/16, ទំព័រទី៤ ។

[12] របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង, ២៩ ធ្នូ ២០១០, D2/22, ត្រង់ទំព័រទី៧ ។ *សូមអានផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូច សឿលី, ១០ វិច្ឆិកា ២០១០, D2/15, ទំព័រទី៧ ។

[13] របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង, ២៩ ធ្នូ ២០១០, D2/22, ត្រង់ទំព័រទី២ ។ របាយការណ៍បញ្ជាក់ថា មិនមែនគ្រប់សាក្សីដែលអាចរកបានទាំងអស់ត្រូវបានស្តាប់ចម្លើយនៅពេលនៃការរៀបចំរបស់ខ្លួននោះទេ ។ អ្នកស៊ើបអង្កេតបានចង្អុលបង្ហាញ (ត្រង់ទំព័រទី៥) ពីកត្តាមួយចំនួនដែលតម្រូវឱ្យមានកិច្ចស៊ើបសួរបន្ថែម រួមមាន: អំពីពេលវេលា និងអំឡុងពេលនៃប្រតិបត្តិការរបស់មន្ទីរ, ការប្រព្រឹត្តទៅរបស់មន្ទីរ និងសមត្ថភាពរបស់មន្ទីរ ចំនួនអ្នកជាប់ឃុំឃាំង ការសម្លាប់ និងការប្រព្រឹត្តទៅលើក្រុមជាក់លាក់ ។

[14] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កសព លើឈ្មោះ បុច កុយ (ប៉ុច កុយ), ១២ សីហា ២០០៨, D1.3.13.1 ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ុច កុយ, ២៨ កក្កដា ២០១០, D2/4 ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កសព ទូច ស៊ូលី (ទូច សឿលី), ១៦ សីហា ២០០៨, D1.3.13.13 ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូច សឿលី, ១០ វិច្ឆិកា ២០១០, D2/15 ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូច សឿលី, ១១ វិច្ឆិកា ២០១០, D2/16 ។

[15] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីររបស់សហព្រះរាជអាជ្ញា, ២០ វិច្ឆិកា ២០០៨, ត្រង់កថាខ័ណ្ឌទី៥៥-៥៧ (ប៉ែន សារិន, សុក ឡាង) ។

ជាច្រើនលើកទៅលើកប៉ាល់នេសាទនិងកប៉ាល់នានានៅក្នុងសមុទ្រ[16] ។ មកទល់ពេលនេះភស្តុតាងដែលអាចរកបានបញ្ជាក់ឲ្យឃើញថា បុគ្គលទាំងឡាយដែលត្រូវបានចាប់ខ្លួនតាមរបៀបនេះ ត្រូវបានគេៈ សម្លាប់ក្នុងសមុទ្រ, ដាក់គុកនៅមន្ទីរសន្តិសុខ វត្តឥន្ទញាណ, សម្លាប់នៅតាមទីតាំងនានា/ទីតាំងរណ្ដៅសពរួម នៅកំពង់សោម ឬ បញ្ជូនមកមន្ទីរស-២១ ។ ជនរងគ្រោះ រួមមាន ជនជាតិថៃ វៀតណាម និង ចិន និងហោចណាស់មានពួកបស្ចិមប្រទេសបួននាក់[17] ។ ជាការបន្ថែម ភស្តុតាងទាក់ទិននឹងការចាប់នាវា ស.រ.អា ឈ្មោះម៉ាយ៉ាហ្គេស (Mayaguez) សបញ្ជាក់ឲ្យឃើញថា យ៉ាងហោចណាស់មានទាហានកងម៉ារីនអាមេរិកកាំងបីរូបត្រូវបានចាប់ខ្លួន ដាប់ក្នុងមន្ទីរឃុំឃាំង និងជាចុងក្រោយត្រូវបានសម្លាប់ដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ[18] ។ ដោយសារមានសាក្សីតែប្រាំរូបគត់ត្រូវបានស្ដាប់ចម្លើយមកទល់ពេលនេះ[19] គេត្រូវការកិច្ចស៊ើបសួរបន្ថែមសំខាន់មួយដើម្បីបញ្ជាក់អំពីវិសាលភាពនៃបទឧក្រិដ្ឋដែលបានចោទប្រកាន់ ដែលបានប្រព្រឹត្តដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ ។

១០. អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាអន្តរជាតិ សូមស្នើឲ្យបំពេញកិច្ចស៊ើបសួរបន្ថែមដូចដែលមានចែងខាងក្រោមថែមទៀត ដើម្បីឲ្យបញ្ជាក់ការពិតចំពោះការចោទប្រកាន់ទាំងឡាយដែលបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដែលរួមមានអង្គហេតុដូចតទៅនេះ៖

(ក) អំពីការទទួលខុសត្រូវរបស់កងពលធំលេខ១៦៤ ចំពោះមន្ទីរសន្តិសុខវត្តឥន្ទញាណ និង ចំពោះកិច្ចប្រតិបត្តិការតាមសមុទ្ទ (ដែលរួមទាំងការវាយប្រហារទៅលើកប៉ាល់បរទេសផង)។

---

[16] របាយការណ៍ស្ដីពីការកំណត់អត្តសញ្ញាណទីកន្លែង, វត្តឥន្ទញាណ, ២៩ ធ្នូ ២០១០, D2/22, ត្រង់ទំព័រទី២ ។ របាយការណ៍ស្ដីពីការកំណត់អត្តសញ្ញាណទីកន្លែង, ការដ្ឋានវាយថ្មស្ទឹងហាវ, ៣០ ធ្នូ ២០១០, D2/23, ត្រង់ទំព័រទី៤ ។

[17] បញ្ជីឈ្មោះជនបរទេសដែលបានកម្ទេចនៅ ស-២១, ៣១ កក្កដា ២០០២, D4.1.5 (ដោយកត់សំគាល់ថា អ្នកទោសថៃ វៀតណាម និង ចិន ត្រូវបានចាប់ខ្លួននៅកំពង់សោម) ។ បញ្ជីឈ្មោះអ្នកត្រូវបានចាប់ខ្លួនពីកងពលធំ១៦៤, ២៥ មករា ២០០៨, D1.3.11.3 ។

[18] Ralph Wetterhahn (2002), *សមរភូមិចុងក្រោយ (The Last Battle)*, ទំព័រទី ២៨១-២៨៩ ។ សាក្សីផ្ទាល់ផ្ដល់ហេតុការណ៍ថា នៅពេលចាប់ខ្លួនដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ កងម៉ារីនម្នាក់ (វរៈសេនីយ៍ទោ ចូសឹប អិន ហាហ្គ្រូវ - LCpl Joseph N. Hargrove) ត្រូវបានសម្លាប់ភ្លាម ខណៈកងម៉ារីនពីរនាក់ទៀត (PFC Gary L. Hall និង PVT Danny G. Marshall) ត្រូវបានគេបញ្ជូនទៅវត្តឥន្ទញាណ ជាទីកន្លែងដែលពួកគេត្រូវជាប់គុក និងនៅចុងក្រោយត្រូវបានសម្លាប់ ។

[19] កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ញូង ជ្រេង, ចុះថ្ងៃទី២៤ សីហា ២០១០, D2/6 ។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សយ ប៊ិន, ៦ កញ្ញា ២០១០, D2/9 ។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សយ ប៊ិន, ៧ កញ្ញា ២០១០, D2/10 ។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សយ ប៊ិន, ៩ កញ្ញា ២០១០, D2/10 ។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ទូច សឿលី, ១០ វិច្ឆិកា ២០១០, D2/15, ទំព័រទី៦ ។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ទូច សឿលី, ១១ វិច្ឆិកា ២០១០, D2/16 ។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប៉ែន សារិន, ២៦ សីហា ២០១០, D2/7 ។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អ៊ិន សារឿន, ១២ វិច្ឆិកា ២០១០, D2/17 ។

(ខ) អំពីការបង្កើត, កិច្ចដំណើរការការងារ, និងរចនាសម្ព័ន្ធសិទ្ធិអំណាច នៅក្នុងមន្ទីរសន្តិសុខវត្តឥន្ទញាណ, ចំនួន និងសមាសភាពនៃជនរងគ្រោះនានា(ដែលរួមទាំងថា តើអតីតពួកយោធាភូមិភាគបូព៌ាដែលត្រូវបានបោសសំអាតចេញពីក្នុងកងពលធំលេខ១៦៤ត្រូវបានគេដាក់ក្នុងមន្ទីរឃុំឃាំងនៅវត្តឥន្ទញាណដែរ ឬទេ?), នីតិវិធីទាក់ទងនឹងការចាប់ខ្លួន, ការដាក់ក្នុងមន្ទីរឃុំឃាំង និងការសួរចម្លើយនៃពួកអ្នកទោស(បើសិនជាមាន), ស្ថានភាពជនរងគ្រោះនៅពេលត្រូវគេដាក់ក្នុងមន្ទីរឃុំឃាំង ហើយនិងការធ្វើបាបផ្សេងៗដែលពួកគេបានទទួលរង។

(គ) អំពីការបាត់ខ្លួន និងការសម្លាប់អ្នកទោស និងមនុស្សផ្សេងទៀតដែលត្រូវកងកម្លាំងនៃកងពលធំលេខ១៦៤ចាប់បាន ទាំងនៅក្នុងបរិវេណវត្តឥន្ទញាណ និងទាំងនៅកន្លែងដទៃទៀតក្នុងតំបន់កំពង់សោម ព្រមទាំងទីតាំងនៃរណ្តៅសពបន្ថែមថ្មីៗទៀត។

(ឃ) អំពីតួនាទីនៃមន្ទីរសន្តិសុខវត្តឥន្ទញាណក្នុងការដាក់ជនរងគ្រោះក្នុងមន្ទីរឃុំឃាំង ដែលក្រោយមកត្រូវបានគេបញ្ជូនទៅកាន់មន្ទីរស-២១, កាលៈទេសៈនៃការបញ្ជូនទាំងនោះ, និងតើពួកជនដែលត្រូវបានគេផ្តល់អត្តសញ្ញាណនៅក្នុងចម្លើយសារភាពនានាដែលស្រង់ដោយមន្ទីរស-២១ បន្ទាប់មកមានត្រូវបានគេចាប់ខ្លួនហើយដែលដាក់នៅក្នុងមន្ទីរឃុំឃាំងនៅមន្ទីរសន្តិសុខវត្តឥន្ទញាណដែរឬទេ?។និង

(ង) ដើមកំណើត សមាសភាព និងចំនួនសរុបនៃជនជាតិបរទេសដែលត្រូវបានចាប់ខ្លួននៅក្នុងសមុទ្ទ ឬដែលត្រូវបានសម្លាប់ដោយកងពលធំលេខ១៦៤ ហើយនិងថាតើពួកជនជាតិបរទេសដែលត្រូវបានចាប់ខ្លួនដោយកងពលធំលេខ១៦៤ទាំងនេះមានត្រូវបានគេបញ្ជូនទៅកាន់មន្ទីរសន្តិសុខវត្តឥន្ទញាណ ឬស-២១ដែរ ឬទេ?។

១១. សហព្រះរាជអាជ្ញាអន្តរជាតិ សូមស្នើឱ្យបំពេញកិច្ចស៊ើបសួរជាក់លាក់ទាក់ទងទៅនឹងទីកន្លែងនានា គឺមានដូចតទៅនេះ៖

(ក) ធ្វើសម្ភាសន៍ឡើងវិញលើសាក្សីឈ្មោះ សយ ប៊ន (Say Born), ទូច សឿលី (Touch Soeuli), អ៊ុន សារឿន(In Sarouen), ប៉ែន សារិន (Pen Sarin), និង ញ៉ុង ជ្រោង (Nhoung Chrong) ទាក់ទងនឹងកិច្ចដំណើរការការងារនៃមន្ទីរសន្តិសុខវត្តឥន្ទញាណ, ការចាប់ខ្លួននៅក្នុងសមុទ្ទ, និងរណ្តៅសពរួមដែលស្ថិត នៅក្នុងតំបន់ ហើយនិងស្នើឱ្យពួកគេបញ្ជាក់អំពីទីកន្លែងដែលកំពុងស្ថិតនៅបច្ចុប្បន្ននៃសាក្សីបន្ថែមថ្មីៗដែលមានសក្តានុពល។

(ខ) ធ្វើសម្ភាសន៍សាក្សីឈ្មោះ សុខ ឡាង (Sok Lang) និង អ្នកដាក់ពាក្យសុំតាងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ Rob Hamill, ដែលធ្លាប់ធ្វើការស្រាវជ្រាវយ៉ាងច្រើនសន្ធឹកសន្ធាប់អំពីការចាប់ខ្លួន និងការបញ្ជូនបងរបស់គាត់ឈ្មោះ Kerry Hamill ទៅកាន់មន្ទីរស-២១ ដោយអង្គភាព/កងវរៈសេនាធំលេខ១៤០ របស់កងពលធំលេខ១៦៤។

(គ) កំណត់ទីតាំង និងធ្វើសម្ភាសន៍បណ្តាអតីតកម្មាភិបាល និងសាក្សីផ្សេងៗទៀតដែលមានសក្តានុពលដែលត្រូវបានស្គាល់អត្តសញ្ញាណនៅក្នុងពេលសម្ភាសន៍ដែលបានធ្វើឡើងរហូតមកទល់ពេលនេះដែលរួមមានឈ្មោះ៖

i. សរ សាមឿន (ហៅ តាមឿន) (Sar Samoeun alias Ta Moeun), មេបញ្ជាការកាលពីដំបូងរបស់កងវរៈសេនាតូច៤៥០, ដែលជាអង្គភាពប្រតិបត្តិការនៅមន្ទីរសន្តិសុខវត្តអង្គតាញាណ[20]។

ii. តា ណន (Ta Norn), ដែលហាក់ដូចជាបានបន្តពី តា មឿន (Ta Moeun)មក[21]។

iii. នង ឆាន/សួន ឆាន/ណាន ឆាន (Norng Chhan / Suon Chhan / Nan Chhan), សមាជិកនៃគណៈកម្មការកងពលធំលេខ១៦៤ ដែលជាអ្នកទទួលការខុសត្រូវនៃតំបន់ស្ទឹងហាវ[22]។

iv. ហាន/ហុន (Han / Hon), មេបញ្ជាការកងវរៈសេនាធំលេខ១៤០ (នៃកងម៉ារីនរបស់កងពលធំលេខ១៦៤) និងជាអតីមេបញ្ជាការនៃកងវរៈសេនាតូចលេខ៥៥០ (កាលពីមុននេះជាកងវរៈសេនាតូចលេខ ត-៤ (T-4) នៅតំបន់១៣)[23]។

---

[20] កំណត់ហេតុស្តាប់ចម្លើយសាក្សីឈ្មោះ ទូច សឿលី (Touch Soeuli), ចុះថ្ងៃទី១០ វិច្ឆិកា ២១០១០, ឯកសារលេខ D2/15 ត្រង់ទំព័រ៥-៨ 5-8.។ សរ សាមឿន (Sar Samoeun) ដែលតាមរបាយការណ៍ថាបានរស់នៅវត្តឥន្ទញាណជាមួយសាក្សីចាប់តាំងពីខែសីហា ១៩៧៥មក។

[21] ដូចគ្នានឹងខាងលើ ត្រង់ទំព័រ៨។ ឈ្មោះ នន (Norn) តាមរបាយការណ៍ថាត្រូវបានគេចាប់ខ្លួននៅក្នុងឆ្នាំ១៩៧៧/៧៨ ពីបទចាប់រំលោភសេពសន្ថវៈអ្នកទោសស្ត្រីម្នាក់ ប៉ុន្តែបន្ទាប់ពីនោះមកទីកន្លែងដែលគាត់កំពុងស្ថិតនៅមិនត្រូវបានគេបញ្ជាក់ច្បាស់ទេ។ របាយការណ៍ស្តីពីការកំណត់ទីតាំង, ចុះថ្ងៃទី២៩ ធ្នូ ២០១០,ឯកសារ D2/22, ត្រង់ទំព័រ 6។

[22] កំណត់ហេតុស្តាប់ចម្លើយសាក្សីឈ្មោះ ទូច សឿលី (Touch Soeuli), ជុំថ្ងៃទី១១ វិច្ឆិកា ២០១០, ឯកសារលេខ D2/16, ត្រង់ទំព័រ៤។ កំណត់ហេតុស្តាប់ចម្លើយសាក្សីឈ្មោះ ប៉ែន សារិន (Pen Sarin), ចុះថ្ងៃទី២៦ សីហា ២០១០, ឯកសារលេខ D2/7, ត្រង់ទំព័រ៣ ។ កំណត់ហេតុស្តាប់ចម្លើយសាក្សីឈ្មោះ សយ ប៊ិន (Say Born), ចុះថ្ងៃទី៧ កញ្ញា ២០១០, ឯកសារលេខ D2/9, ត្រង់ទំព័រ៦។

[23] កំណត់ហេតុស្តាប់ចម្លើយសាក្សីឈ្មោះ សយ ប៊ិន (Say Born), ចុះថ្ងៃទី៧ កញ្ញា ២០១០, ឯកសារលេខ D2/9, ត្រង់ទំព័រ៦។

v. តា ង៉ែត (Ta Nget), មេបញ្ជាការកងវរៈសេនាធំលេខ២០ (១៦១)របស់កងពលធំលេខ ១៦៤[24]។

vi. មាញ (Meanh), មេបញ្ជាការកងវរៈសេនាធំលេខ២១(១៦២)របស់កងពលធំលេខ ១៦៤[25]។

vii. តា យ៉ាន (Ta Yan), មេបញ្ជាការកងវរៈសេនាធំលេខ២២(១៦៣)របស់កងពលធំលេខ ១៦៤ និងមេបញ្ជាការរងរបស់គាត់ឈ្មោះ ស្រស់ និងញ៉ាន (Sras and Nhan)[26]។

viii. បូ (Bo), មេបញ្ជាការកងវរៈសេនាធំលេខ១៤០, ផ្នែកនាវាប្រដេញ, ដែលបច្ចុប្បន្ននេះ កំពុងរស់នៅស្រែអំបិល[27]។

ix. សុខ ភាព (ហៅ ភាព) (Sok Peap alias Pheap), ដែលត្រូវបានសាក្សីម្នាក់ផ្តល់អត្តសញ្ញាណថា ជាប្រធានកងវរៈសេនាធំលេខ១៦២[28]។

x. រីម (Reem), ដែលត្រូវបានគេស្គាល់អត្តសញ្ញាណថា ជាអ្នកទោសស្ត្រីម្នាក់ដែលគេបាន អះអាងថា ត្រូវបាន តា នន ចាប់រំលោភសេពសន្ថវៈនៅក្នុងឆ្នាំ១៩៧៧/៧៨[29]។ និង

---

កំណត់ហេតុធ្វើសម្ភាសន៍សាក្សីឈ្មោះ ទូច ស៊ូលី (ទូច សឿលី)(Touch Souley /Touch Soeuli)ដែលស្រង់ដោយ កសព, ចុះថ្ងៃទី ១៦ សីហា ២០០៨, ឯកសារលេខ D1.3.13.13, ត្រង់ទំព័រ៤ ,៦។ កំណត់ហេតុស្តាប់ចម្លើយសាក្សីឈ្មោះ ញួង ជ្រុង ( Nhoung Chrong), ចុះថ្ងៃទី២៤ សីហា ២០១០, ឯកសារលេខ D2/6, ត្រង់ទំព័រ ៥។

[24] កំណត់ហេតុស្តាប់ចម្លើយសាក្សីឈ្មោះ សយ ប៊ន (Say Born), ចុះថ្ងៃទី៦ កញ្ញា ២០១០, ឯកសារ D2/8 ត្រង់ទំព័រ៧។

[25] ដូចគ្នានឹងខាងលើ ត្រង់ទំព័រ៨។

[26] ដូចគ្នានឹងខាងលើ ត្រង់ទំព័រ៧។ កំណត់ហេតុធ្វើសម្ភាសន៍សាក្សីឈ្មោះ ទូច ស៊ូលី (ទូច សឿលី) (Touch Soeuli) ដែលស្រង់ដោយ កសព, ចុះថ្ងៃទី ១៦ សីហា ២០០៨, ឯកសារលេខ D1.3.13.13, ត្រង់ទំព័រ៦។

[27] កំណត់ហេតុស្តាប់ចម្លើយសាក្សីឈ្មោះ សយ ប៊ន (Say Born), ចុះថ្ងៃទី៧ កញ្ញា ២០១០, ឯកសារលេខ D2/9, ត្រង់ទំព័រ៦-៧។ កំណត់ហេតុធ្វើសម្ភាសន៍សាក្សីឈ្មោះ សៀង (Sieng) ដែលស្រង់ដោយ កសព, ចុះថ្ងៃទី២០ វិច្ឆិកា ២០០៨, ឯកសារលេខ D1.3.13.11, ត្រង់ទំព័រ២។

[28] កំណត់ហេតុធ្វើសម្ភាសន៍សាក្សីឈ្មោះ សៀង (Sieng) ដែលស្រង់ដោយ កសព, ចុះថ្ងៃទី២០ វិច្ឆិកា ២០០៨, ឯកសារលេខ D1.3.13.11, ត្រង់ទំព័រ២។

[29] កំណត់ហេតុស្តាប់ចម្លើយសាក្សីឈ្មោះ ទូច សឿលី (Touch Soeuli), ចុះថ្ងៃទី១០ វិច្ឆិកា ២០១០, ឯកសារលេខ D2/15, ត្រង់ទំព័រ៨។

xi. គឹងសង្គម(Keung Sangkum), មន្ត្រីមូលដ្ឋានដែលបានបញ្ជាឲ្យផ្នែកសាធារណៈការប្រមូលឆ្អឹងសាកសពដែលរកឃើញជិតវត្តឥន្ទញាណ ហើយយកទៅដាក់នៅក្នុងស្តូបដាក់អដ្ឋិធាតុដែលនៅនឹងកន្លែង[30]។

(ឃ) កំណត់ទីតាំង និងស្តាប់ចម្លើយពួកអតីតកម្មាភិបាល និងសាក្សីសក្តានុពលដទៃទៀត ដែលឈ្មោះរបស់ពួកគេមាននៅក្នុងភស្តុតាងជាឯកសារ រួមមាន៖ សាមៀន (Samean) - បញ្ជាការជើងទឹក[31], មឿន (Meuan) - បញ្ជាការ**កងវរសេនាតូចលេខ ៤៥០**[32] (អាចជាមនុស្សតែមួយដូចគ្នានឹងឈ្មោះ មឿន (Moeun) ដែលបានយោងនៅខាងលើ) ។ កម្មាភិបាល**កងវរសេនាតូចលេខ ៣៨៦** ដែលគេឲ្យឈរជើងនៅកោះតាង (**កងអនុសេនាធំលេខ ៩០៨៖** សំណាង (Somnang) - បញ្ជាការ, លឹម (Lim) - អនុបញ្ជាការ, សុង (Song) - សមាជិក ។ **កងអនុសេនាធំលេខ ៩២០៖** ចាន់ ប៊ុនថុន (Chan Bunthon) - បញ្ជាការ, តួយ (Tuoy) - សមាជិក, មាស ញ៉ែម (*ហៅ* ខុន) (MEAS Nhem (*alias* Khon)) - សមាជិក, មៀន (Mean) - សមាជិក, ឈិន (Chhin) - សមាជិក)[33] ។ កម្មាភិបាល**កងពលធំលេខ ១៦៤៖** ណុង ឆន (NONG Chhan) - កម្មាភិបាលនយោបាយ/បញ្ជាការ[34] ដែលអាចជាមនុស្សតែមួយដូចគ្នានឹងសមាជិកកងពលធំលេខ ១៦៤ ដែលបានកំណត់អត្តសញ្ញាណនៅខាងលើ ។ ម៉ុល ម៉ុន (MOL Mon) - បុគ្គលិកផ្នែកវ៉ាដាដែលឈរជើងនៅកោះតាង[35] និងពួកកម្មាភិបាលកងពលធំលេខ ១៦៤ ឈ្មោះ ឯក នី (AEK Ny) (ដែលធ្លាប់បានផ្តល់

[30] កំណត់ហេតុស្តាប់ចម្លើយសាក្សីឈ្មោះ ប៉ូច កុយ (Pauch Koy), ចុះថ្ងៃទី២៨ កក្កដា ២០១០, ឯកសារលេខ D2/4, ត្រង់ទំព័រ៨។

[31] ឯកសារក្នុងសំណុំរឿងលេខ០០២៖ ការសួរយកការណ៍ដោយស.រ.អា ពីកម្មាភិបាលអនាមិកនៃកងពលធំលេខ៣, ថ្ងៃទី៨ ធ្នូ ១៩៩៨, D223.3, ត្រង់ទំព័រទី ២០ (ឯកសារត្រូវបានដាក់ជូនដោយសហព្រះរាជអាជ្ញាអន្តរជាតិ) ។

[32] ឯកសារក្នុងសំណុំរឿងលេខ០០២៖ ការសួរយកការណ៍ដោយស.រ.អា ពីកម្មាភិបាលអនាមិកនៃកងពលធំលេខ៣, ថ្ងៃទី៨ ធ្នូ ១៩៩៨, D223.3, ត្រង់ទំព័រទី ២០ (ឯកសារត្រូវបានដាក់ជូនដោយសហព្រះរាជអាជ្ញាអន្តរជាតិ) ។

[33] ការសួរយកការណ៍ដោយស.រ.អា ពីឈ្មោះ ឯក នី (Mr. Aek Ny) (អតីតកម្មាភិបាលកងវរសេនាតូចលេខ ៣៨៦), ថ្ងៃទី១៩ ធ្នូ ២០០២, លេខERN 00387285-387292, ត្រង់ទំព័រទី ៩ និង ១២ (ឯកសារត្រូវបានដាក់ជូនដោយសហព្រះរាជអាជ្ញាអន្តរជាតិ) ។

[34] ការសួរយកការណ៍ដោយស.រ.អា ពីឈ្មោះ ឯក នី (Mr. Aek Ny) (អតីតកម្មាភិបាលកងវរសេនាតូចលេខ ៣៨៦), ថ្ងៃទី១៩ ធ្នូ ២០០២, លេខERN 00387285-387292, ត្រង់ទំព័រទី១៣ (ឯកសារត្រូវបានដាក់ជូនដោយសហព្រះរាជអាជ្ញាអន្តរជាតិ) ។ ការសួរយកការណ៍លើកទី១ ដោយស.រ.អា ពីឈ្មោះ មាស មុត, ថ្ងៃទី៥ ធ្នូ ២០០១, លេខERN 00249692-249700, ត្រង់ទំព័រទី១១ (ឯកសារត្រូវបានដាក់ជូនដោយសហព្រះរាជអាជ្ញាអន្តរជាតិ) និង ការសួរយកការណ៍លើកទី២ ដោយស.រ.អា ពីឈ្មោះ មាស មុត, ថ្ងៃទី៣០ ឧសភា ២០០២, លេខERN 00249701-249707, ត្រង់ទំព័រទី៥ និង ៦ (ឯកសារត្រូវបានដាក់ជូនដោយសហព្រះរាជអាជ្ញាអន្តរជាតិ) ។

[35] ឯកសាររបស់ Joint Casualty Resolution Center ដែលមានចំណងជើងថា៖ *របាយការណ៍ជនភៀសខ្លួន, ការមើលឃើញគ្រោងឆ្អឹងចំនួនពីរ៖ មរណភាពទាក់ទងនឹងនាវាម៉ាយ៉ាហ្គេស* (*Refugee Report, Sighting of Two Skeletons: Mayaguez Related Death*), ថ្ងៃទី២៥ មេសា ១៩៨៣, ត្រង់ទំព័រទី ២ - ឯកសារទាំងនេះ យោងទៅដល់ការស៊ើបអង្កេតយ៉ាងទូលំទូលាយ ដែលបានធ្វើឡើងនៅឆ្នាំ១៩៩៥ និង ១៩៩៦ (ឯកសារត្រូវបានដាក់ជូនដោយសហព្រះរាជអាជ្ញាអន្តរជាតិ) ។

បទសម្ភាសន៍ជាមួយអ្នកស៊ើបអង្កេត ស.រ.អា) និងឈ្មោះ បែន ឈឿន (BAEN Cheoun)[36] និងអ្នកបើកយន្តហោះ ផេង ហុក (PHENG Hok)[37] ។

(ង) កំណត់ទីតាំង និងស្តាប់ចម្លើយពួកអតីតកម្មាភិបាលដទៃទៀតនៃកងពលធំលេខ ១៦៤ ដែល មាស មុត បានកំណត់អត្តសញ្ញាណនៅក្នុងការសួរយកការណ៍នានាពីសំណាក់អ្នកស៊ើបអង្កេត ស.រ.អា[38]៖ រស់ ឡន (ROS Lan) - នីរសា, កំ ម៉ែន (KAM Men) - បញ្ជាការកងអនុសេនាធំ ក្នុងកងពលធំលេខ ៣, គង់ ឆាយ (KONG Chhay) - បញ្ជាការកងហានៅកោះតាង, ម៉ៅ រ៉ាន (MAO Ran) - កម្មាភិបាលក្នុងកងពលធំលេខ៣, ខែម ងន់ (KHEM Ngon) - បញ្ជាការកងហា ក្នុងកងពលធំលេខ៣ ឈរជើងនៅកំពង់សោម, សារឿន (Saroeun) - អនុបញ្ជាការ, ញ៉ន (Nhan) - សមាជិកគណៈកម្មាធិការផ្នែកភស្តុភារ, លន់ (Lon) - ប្រធានផ្នែកភស្តុភារ, ធាន (Thean) - បញ្ជាការកងពិសេស លេខ ១៣០, នន់ (Non) - អនុបញ្ជាការកងពិសេសលេខ ១៣០, ម៉ែន (Men) - បញ្ជាការកងពលធំថ្មើរជើង លេខ៣, ឡូន (Loan) - បញ្ជាការ “កងនេសាទប្រដាប់អាវុធ” ។

(ច) ស្តាប់ចម្លើយពួកអតីតកម្មាភិបាលមន្ទីរស-២១ ពាក់ព័ន្ធនឹងការបញ្ជូនពួកអ្នកទោសជើងទឹកនៃកម្ពុជាប្រជាធិបតេយ្យ ឲ្យទៅមន្ទីរស-២១ រួមមាន៖ ម៉ម ណៃ (*ហៅ* ចាន់) ជាអ្នកសួរចម្លើយម្នាក់នៅមន្ទីរស-២១ ដែលបានសួរចម្លើយអ្នកទោសវៀតណាមជាច្រើននាក់[39] ។ ហ៊ឹម ហ៊ុយ ជាប្រធានកងយាមពិសេសនៅមន្ទីរស-២១ ដែលគួរតែត្រូវបានសួរអំពីនីតិវិធីក្នុងការចាប់ និងបញ្ជូនខ្លួនជនជាតិបរទេសឲ្យទៅមន្ទីរស-២១, និងអំពីការសម្លាប់ពួកទាំងនោះនៅមន្ទីរស-២១[40] ។ ហាន អៀម ជាអតីតអ្នកយាមនៅមន្ទីរស-២១[41] ។

(ឆ) ធ្វើការស្តាប់ចម្លើយបន្ថែមទៀត ពាក់ព័ន្ធនឹងការចាប់ខ្លួន និងការម្លាប់ពួកទាហានកងម៉ារីនបន្ទាប់ពីឧបទ្ទវហេតុនាវាម៉ាយ៉ាហ្គេស (Mayaguez) ដោយ៖

---

[36] ដូចខាងលើ, ត្រង់ទំព័រទី ៤ ។ ឯក នី (Mr. Aek Ny) ជាសក្ខីភាពល អាចកំណត់ទីកន្លែងបាននៅ ភូមិជីមាល ឃុំអណ្តូងទឹក ស្រុកបុទុមសាគរ ខេត្តកោះកុង និង បែន ឈឿន (Baen Cheoun) ជាសក្ខីភាពល អាចកំណត់ទីកន្លែងបាននៅ ស្រុកអង្គរជ័យ ខេត្តកំពត ។

[37] ឯកសារសំណុំរឿងលេខ០០២ Henri LOCARD បណ្តាញគុកកម្ពុជាប្រជាធិបតេយ្យក្នុងតំបន់បូព៌ា ឧសភា ២០០៧ D313/1.2.18 នៅទំព័រ ៦ (ឯកសារកំពុងត្រូវបានដាក់ដោយសហព្រះរាជអាជ្ញាអន្តរជាតិ)។

[38] ការសួរយកការណ៍លើកទី១ ដោយស.រ.អា ពីឈ្មោះ មាស មុត, ថ្ងៃទី៥ ធ្នូ ២០០១, លេខERN 00249692-249700, ត្រង់ទំព័រទី៨, ១១-១២ (ឯកសារត្រូវបានដាក់ជូនដោយសហព្រះរាជអាជ្ញាអន្តរជាតិ) ។ ការសួរយកការណ៍លើកទី២ ដោយស.រ.អា ពីឈ្មោះ មាស មុត, ថ្ងៃទី៣០ ឧសភា ២០០២, លេខERN 00249701-249707, ត្រង់ទំព័រទី ៦ (ឯកសារត្រូវបានដាក់ជូនដោយសហព្រះរាជអាជ្ញាអន្តរជាតិ) ។

[39] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ម ណៃ *ហៅ* ចាន់, ថ្ងៃទី៤ កុម្ភៈ ២០០៨, D50/2, ត្រង់ទំព័រទី ៤ ។

[40] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ឹម ហ៊ុយ, ថ្ងៃទី១៨ កញ្ញា ២០០៧, D19/V, ត្រង់ទំព័រទី ៦-៧ ។ សក្ខីកម្មរបស់ ហ៊ឹម ហ៊ុយ, សំណុំរឿងលេខ ០០១, ថ្ងៃទី១៦ កក្កដា ២០០៩, T.12 ។

[41] ហាន អៀម, ថ្ងៃទី១០ មករា ២០០២, កំណត់ហេតុរបស់ DC-Cam, D1.3.32.12 (ដោយបានកត់សម្គាល់ថាមានអ្នកនេសាទថៃគ្រប់គ្រាន់ល្មម បានជាប់ឃុំឃាំងនៅ មន្ទីរស-២១ ដែល ម៉ឹង អាចរៀនថៃបានល្មមនឹងធ្វើការប្រាស្រ័យទាក់ទងជាមួយពួកគេ) ។

(i) ធ្វើការស្តាប់ចម្លើយឈ្មោះ Ralph Wetterhahn ជាអ្នកនិពន្ធសៀវភៅ "សង្គ្រាមចុងក្រោយ" (The Last Battle) ដែលលើសពីអ្វីៗទាំងអស់ គាត់បានរៀបរាប់ពីការឃុំឃាំងបុគ្គលិកយោធា ស.រ.អា នៅមន្ទីរសន្តិសុខវត្តឥន្ទញាណ[42], ដាក់ច្បាប់ចម្លងសៀវភៅនេះចូលទៅក្នុងសំណុំរឿង និង ធ្វើឲ្យដឹងប្រាកដអំពីកន្លែងដែលត្រូវសាកសួរនៅក្នុងសៀវភៅនោះ ។

(ii) ធ្វើការស្តាប់ចម្លើយឈ្មោះ អែម សុន ជាអតីតបញ្ជាការនៃកម្ពុជា ប្រជាធិបតេយ្យ អំពីចម្លើយរបស់គាត់ស្តីពីការចាប់ខ្លួន និងការសម្លាប់ ដែលត្រូវបានរាយការណ៍ក្នុងសៀវភៅ "សង្គ្រាមចុងក្រោយ" (The Last Battle) ។

(ជ) ធ្វើការស្តាប់ចម្លើយបន្ថែមទៀតអំពីទីកន្លែងកប់សព ដែលបានកំណត់អត្តសញ្ញាណរួចហើយ៖

(i) **ចំការក្រូចឆ្មារ (Lemon Plantation)** - គេគួរតែធ្វើការស៊ើបសួរបន្ថែមទៀតពាក់ព័ន្ធនឹងប្រភព ចំនួន និង ស្ថានភាពនៃអដ្ឋិធាតុមនុស្សនៅសល់ដែលគេបានរកឃើញ (គេគួរតែស្តាប់ចម្លើយសាក្សីឈ្មោះ គឹង សង់គំ (Keung Sangkum) ដើម្បីជួយក្នុងការទៅមើលទីតាំងនេះ)[43] ។

(ii) **ចំការធូរេន (Durian Plantation)** - ទីកន្លែងផ្នូរសាកសពរួម មានទីតាំងនៅក្បែរវត្តឥន្ទញាណ ។ វាជាការច្បាស់ណាស់ដែលថាសាក្សីឈ្មោះ ទូច សឿលី បានដឹងថាមានកន្លែងកប់សាកសព និងនៅមិនទាន់បានផ្តល់ព័ត៌មានគ្រប់ទាំងអស់ដែលគាត់មាននៅឡើយ[44]។ សាក្សីឈ្មោះ ញូង ជ្រោង និង អ៊ុន សារឿន ក៏បានផ្តល់ភស្តុតាងពាក់ព័ន្ធនឹងការសម្លាប់ និងកប់សាកសពនៅកន្លែងនេះផងដែរ[45] ។ ការទៅមើលទីតាំង គួរតែត្រូវបានធ្វើឡើងដោយមានការជួយជ្រោមជ្រែងពីសាក្សីទាំងនេះ ។

---

[42] របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង, ថ្ងៃទី២៩ ធ្នូ ២០១០, D2/22, ត្រង់ទំព័រទី ២, ៨ ៖ "Ralph Wetterhahn, 'សង្គ្រាមចុងក្រោយ - The Last Battle', ISBN 0-452-28333-7" ។

[43] ដូចខាងលើ, ត្រង់ទំព័រទី ៦, ១៧ ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ូច កុយ, ថ្ងៃទី២៨ កក្កដា ២០១០, D2/4, ត្រង់ទំព័រទី ៨ ។

[44] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូច សឿលី, ថ្ងៃទី១១ វិច្ឆិកា ២០១០, D2/16, ត្រង់ទំព័រទី ៦ ។

[45] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញូង ជ្រោង, ថ្ងៃទី២៤ សីហា ២០១០, D2/6, ត្រង់ទំព័រទី ៩-១០ ។ យោងតាមឈ្មោះ ញូង ជ្រោង កងវរសេនាធំលេខ ៦២ បានយកមនុស្សពី រាម ដែលជាសេនាធិការដ្ឋានរបស់ទាហានកងម៉ារីន ទៅកាន់ចំការធូរេនដើម្បីសម្លាប់ចោល ហើយប្រើប្រាស់ធ្វើជាជី ដែលរួមមាន អ្នកទោសថៃ និង អ្នកទោសវៀតណាម ។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុន សារឿន, ថ្ងៃទី១២ វិច្ឆិកា ២០១០, D2/17 ។

(ឈ) កាលណាមានការចាំបាច់ដើម្បីធ្វើការផ្ទៀងផ្ទាត់ និងបញ្ជាក់ព័ត៌មាន ត្រូវឲ្យសាក្សីនានាដែលបានកំណត់អត្តសញ្ញាណខាងលើធ្វើការតទល់គ្នា ។

(ញ) បំពេញគ្រប់សកម្មភាពដទៃទៀតទាំងអស់ ដែលអ្នកស៊ើបអង្កេតបានផ្តល់អនុសាសន៍នៅក្នុងរបាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីតាំង និង ធ្វើបច្ចុប្បន្នភាពលើរបាយការណ៍នោះ ។

## ការដ្ឋានវាយថ្មស្ទឹងហាវ និងទីតាំងដែលពាក់ព័ន្ធ

១២. សកម្មភាពស៊ើបសួរដែលបានធ្វើឡើងមកទល់ពេលនេះ បានបញ្ជាក់អះអាងអំពី អត្ថិភាពនៃទីតាំងពលកម្មដោយបង្ខំនៅការដ្ឋានវាយថ្ម ដែលមានទីតាំងស្ថិតនៅជិត ស្ទឹងហាវ ខេត្តកំពង់សោម[46] ។ ទីតាំងពីរទៀតក៏បានស្គាល់ផងដែរៈ ផែមួយ និងផ្លូវមួយនៅស្ទឹងហាវ ដែលសំណង់ទាំងពីរសុទ្ធតែបានកសាងឡើងដោយប្រើប្រាស់ថ្មពីកន្លែងវាយថ្មនេះ និងថាដូច្នេះហើយ សំណង់ទាំងពីរបានជាប់ទាក់ទងដោយផ្ទាល់ទៅនឹងទីតាំងចំបង[47] ។ សហព្រះរាជអាជ្ញាអន្តរជាតិបំភ្លឺថាដូចដែលទីតាំងទាំងនេះបង្កើតបានជាផ្នែកនៃទីតាំងការដ្ឋានពលកម្មដោយបង្ខំ ដូចបានរៀបរាប់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ស.ច.ស មានសិទ្ធិ និងតម្រូវឲ្យស៊ើបសួរទៅលើទីតាំងទាំងនេះ ។

១៣. ភស្តុតាងនានាដែលប្រមូលបានមកទល់ពេលនេះបញ្ជាក់ថា ទីតាំងត្រូវបានធ្វើប្រតិបត្តិការដោយកងពលធំ១៦៤ របស់កងទ័ពបដិវត្តន៍កម្ពុជា ប្រហែលចាប់ពីពាក់កណ្តាលឆ្នាំ១៩៧៥/ដើមឆ្នាំ១៩៧៦ រហូតដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ[48]។ ភស្តុតាងក៏អះអាងដែរថា ជនរងគ្រោះដែលត្រូវបានគេធ្វើឲ្យទៅជាទាសករនៅការដ្ឋាននេះ រួមមាន មនុស្សដែលគេគិតថា "មាននិន្នាការ" ឬ "សមាសភាពមិនល្អ" និងថា ជនរងគ្រោះ ត្រូវបានគេដាក់ឲ្យស្ថិតក្រោមពលកម្មការងារដោយបង្ខំ

---

[46] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កសព លើឈ្មោះ សៀង, D1.3.13.11, ១២ សីហា ២០០៨ ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កសព លើឈ្មោះ ប៉ែន សារិន, D1.3.13.8, ១៣ សីហា ២០០៨ ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ែន សារិន, D2/7, ២៦ សីហា ២០១០ និង របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង, D2/23, ៣០ ធ្នូ ២០១០, ត្រង់ទំព័រទី៥ ។

[47] របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង, D2/23, ៣០ ធ្នូ ២០១០, ត្រង់ទំព័រទី២, ៥, ២២ និង ២៦ ។

[48] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កសព លើឈ្មោះ សៀង, D1.3.13.11, ១២ សីហា ២០០៨, ត្រង់ទំព័រទី៤ និង របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង, D2/23, ៣០ ធ្នូ ២០១០, ត្រង់ទំព័រទី៥ ។

"យ៉ាងលំបាប"[49] ។ កម្មករដែលមានកំហុស និងជនណាដែលគេកំណត់ថា មានការជាប់ទាក់ទិននឹងរបបចាស់ ត្រូវបានគេហៅទៅបាត់ និងបាត់ខ្លួនតែម្តង[50] ។

១៤. ដូចរបាយការណ៍របស់អ្នកស៊ើបអង្កេតសង្កត់ធ្ងន់ថា កិច្ចស៊ើបសួរលើទីតាំងទាំងនេះ មិនទាន់បានបញ្ចប់ទេ[51] ។ អ្នកស៊ើបអង្កេតបានកំណត់បង្ហាញពីចំណុចជាច្រើនដែលតម្រូវឲ្យមានកិច្ចស៊ើបសួរបន្ថែមទៀត រួមមាន: សមាសភាពកម្មករ, លក្ខខណ្ឌការងារ និងការរស់នៅ, ប្រព័ន្ធដាក់ទណ្ឌកម្ម និងអត្រាមរណភាពនៅទីតាំងនេះ, រចនាសម្ព័ន្ធដឹកនាំនៃកងពលធំ១៦៤ ទាក់ទិននឹងទីតាំងនេះ, ការប្រព្រឹត្តលើក្រុមជាក់លាក់ រួមទាំង ទាហានចាស់, អ្នក១៧មេសា និងស្ត្រីដែលធ្វើការនៅទីតាំងនេះ ហើយនិងការចុះទៅពិនិត្យទីតាំងការដ្ឋានធ្វើផ្លូវបន្ថែមទៀត[52] ។

១៥. សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើឲ្យបំពេញកិច្ចស៊ើបសួរដូចបានកំណត់ខាងក្រោមនេះ ដើម្បីស្វែងរកការពិតអំពីការចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ រួមទាំង អង្គហេតុនានាដូចតទៅ៖

(ក) ការទទួលខុសត្រូវរបស់កងពលធំ១៦៤ ចំពោះទីតាំងនេះ និងសិទ្ធិអំណាចជាក់លាក់នៅក្នុងទីតាំង ។

(ខ) ការបង្កើត និងប្រតិបត្តិការរបស់ទីតាំង, លក្ខខណ្ឌការងារ និងការរស់នៅក្នុងទីតាំងនេះ, ចំនួន និងសមាសភាពជនរងគ្រោះ និងការប្រព្រឹត្តចំពោះពួកគាត់[53]; និង

(គ) ការចាប់ខ្លួន និងការបាត់ខ្លួនពីទីតាំង, ទីកន្លែងដែលជនរងគ្រោះត្រូវគេយកទៅ (រួមទាំងមន្ទីរសន្តិសុខវត្តឥន្ទញាណ និង ស-២១) និងការដាក់ក្នុងមន្ទីរឃុំឃាំង ការសម្លាប់ និងការដោះលែងបន្តបន្ទាប់នៅពេលក្រោយមក) ។

---

[49] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កសព លើឈ្មោះ សៀង, D1.3.13.11, ១២ សីហា ២០០៨, ត្រង់ទំព័រទី៤ ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កសព លើឈ្មោះ ប៉ែន សារិន, D1.3.13.8, ១៣ សីហា ២០០៨, ត្រង់ទំព័រទី៣ ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ែន សារិន, D2/7, ២៦ សីហា ២០១០, ត្រង់ទំព័រទី៥ និង របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង, D2/23, ៣០ ធ្នូ ២០១០, ត្រង់ទំព័រទី៧ ។ ប្រភេទបន្ថែមទៀតរបស់ជនរងគ្រោះរួមមាន ទាហាននៃរបបចាស់ និងបងប្អូនរបស់ពួកគាត់, កម្មករ, អ្នកនេសាទ, សមាជិកកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ និងអតីតកម្មាភិបាលភូមិភាគបូព៌ាដែលបានចាប់ខ្លួន ។

[50] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កសព លើឈ្មោះ ប៉ែន សារិន, D1.3.13.8, ១៣ សីហា ២០០៨, ត្រង់ទំព័រទី៣ ។

[51] របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង, D2/23, ៣០ ធ្នូ ២០១០, ត្រង់ទំព័រទី៣ ។

[52] របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង, D2/23, ៣០ ធ្នូ ២០១០, ត្រង់ទំព័រទី៦-៩ ។

[53] មកទល់ពេលនេះភស្តុតាងតែមួយគត់អំពីការដែលគេបានដកជនរងគ្រោះចេញពីទីតាំងនេះទីកាន់ទីកន្លែងណានោះ គឺមានតែតាមរយៈ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កសព លើឈ្មោះ ប៉ែន សារិន ប៉ុណ្ណោះ ដែលសាក្សីរូបនេះនិយាយថា គាត់ "ជឿថា ពួកគេត្រូវបានគេនាំទៅតំបន់បូកគោ នៅក្នុងខេត្តកំពត", កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កសព លើឈ្មោះ ប៉ែន សារិន, D1.3.13.8, ១៣ សីហា ២០០៨, ត្រង់ទំព័រទី៣ ។

១៦. កិច្ចស៊ើបសួរជាក់លាក់ដែលសហព្រះរាជអាជ្ញាអន្តរជាតិ ស្នើឡើងទាក់ទងនឹងទីតាំងទាំងនេះ មាន ដូចខាងក្រោមនេះ ៖

(ក) ស្តាប់ចម្លើយសាក្សីឈ្មោះ សៀង(Sieng) ឡើងវិញ (ដែលមកទល់ពេលនេះបានបដិសេធ មិនព្រមផ្តល់ចម្លើយដល់អ្នកស៊ើបអង្កេត ប៉ុន្តែជាអ្នកដែលមានការដឹងឮយ៉ាងច្រើនពីទីតាំង ទាំងនេះ និង ប៉ែន សារិន (ការចុះទៅពិនិត្យទីតាំងធ្វើផ្លូវមិនបានបញ្ចប់ដោយសារសាក្សី មានជម្ងឺ) ។

(ខ) ស្តាប់ចម្លើយសាក្សីឈ្មោះ ហួរ ជា (HOUR Chea) និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើម បណ្តឹងរដ្ឋប្បវេណីឈ្មោះ ឌុល ស្លុង (DUL Slong) ដែលបានកំណត់អត្តសញ្ញាណនៅ ក្នុងរបាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ប៉ុន្តែមិនបានស្តាប់ចម្លើយពីគាត់ ។

(គ) ស្តាប់ចម្លើយកម្មាភិបាលជាន់ខ្ពស់របស់កងពលធំ១៦៤ ដែលបានកំណត់អត្តសញ្ញាណនៅ ក្នុងបទសម្ភាសន៍មកទល់ពេលនេះ រួមមាន: សុខ ភាព/ភាព ប្រធានកងវរៈសេនាធំ៦២ នៃ កងពលធំ១៦៤[54], ប្វ ជាមេបញ្ជាការផ្នែកនាវាប្រដេញ (កងវរៈសេនាធំ១៤០)[55] និង នង ឆាន ជាសមាជិកកងពលធំ១៦៤ ដែលជាអ្នកមើលការខុសត្រូវលើតំបន់ស្ទឹងហាវ[56] ។

(ឃ) អនុវត្តការស៊ើបសួរបន្តទៀតដើម្បីកំណត់អត្តសញ្ញាណអតីតកម្មាភិបាល និងកម្មការបន្ថែម ទៀត និងបុគ្គលដទៃទៀតដែលមានការដឹងឮពីទីតាំងទាំងនេះ (រួមទាំងស្តាប់ចម្លើយសាក្សី សក្តានុពលនានាដូចបានកំណត់អត្តសញ្ញាណទាក់ទិននឹង វត្តឥន្ទញាណ និងកងទ័ពជើងទឹក កម្ពុជាប្រជាធិបតេយ្យ) ។

(ង) ទទួលឲ្យបានច្បាប់ចម្លងនៃសៀវភៅដែលមានចំណងជើងថា “Quatra Ans Avec Les KR” និពន្ធដោយសាក្សីឈ្មោះ ហួរ ជា រួចដាក់ក្នុងសំណុំរឿងលេខ ០០៣ និងពិនិត្យលើ សៀវភៅនេះ ដើម្បីបានដឹងពីខ្សែសង្វាក់នៃការស៊ើបសួរអំពីទីតាំងទាំងនេះ ។

(ច) បំពេញបញ្ចប់គ្រប់សកម្មភាពទាំងអស់ ដែលបានផ្តល់អនុសាសន៍ដោយអ្នកស៊ើបអង្កេត ក្នុងរបាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ។

## អំពីឧក្រិដ្ឋនានាដែលបានប្រព្រឹត្តនៅក្នុងប្រទេសវៀតណាម

[54] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កសត លើឈ្មោះ សៀង, D1.3.13.11, ១២ សីហា ២០០៨, ត្រង់ទំព័រទី២ ។

[55] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សយ ប៊ិន, ៩ កញ្ញា ២០១០, D2/10, ទំព័រទី៣ ។

[56] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កសត លើឈ្មោះ ប៉ែន សារិន, D1.3.13.8, ១៣ សីហា ២០០៨, ត្រង់ទំព័រទី២ និង ៤ ។

១៧. លើកលែងតែការផ្ទេរឯកសារនានាដែលពាក់ព័ន្ធពីសំណុំរឿងលេខ០០២ចេញ មិនមានកិច្ចស៊ើបសួរសំខាន់ណាត្រូវបានធ្វើឡើងទាក់ទងទៅនឹង មាស មុត និងទៅនឹងការចូលរួមរបស់កងពលធំលេខ ១៦៤ នៅក្នុងឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តនៅក្នុងទឹកដីវៀតណាមឡើយ។ មានសាក្សីមួយរូបដែលត្រូវបានគេធ្វើសម្ភាសន៍ទាក់ទងអំពីតួនាទីរបស់ មាស មុត បានបញ្ជាក់ច្បាស់ថា ពលទាហាននៃកងពលធំលេខ១៦៤ បានចូលរួមចំណែកនៅក្នុងជម្លោះប្រដាប់អាវុធ តែមិនត្រូវបានគេចោទសួរអំពីការចូលរួមរបស់កងពលធំលេខ១៦៤នៅក្នុងឧក្រិដ្ឋកម្មទាំងនេះឡើយ[57]។ ចម្លើយរបស់ឈ្មោះ ឡាយ អ៊ាន (Lay Earn) ដែលត្រូវបានដាក់ភ្ជាប់ជាមួយនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបានបញ្ជាក់ថា កងកម្លាំងរបស់កងទ័ពបដិវត្តន៍កម្ពុជាបានប្រព្រឹត្តបទឧក្រិដ្ឋនានាយ៉ាងធំធេងប្រឆាំងនឹងជនស៊ីវិលនានា ហើយពលទាហាននៃកងពលធំលេខ១៦៤បានចូលរួមចំណែកនៅក្នុងការចូលលុកលុយទាំងនោះ[58]។ ទោះបីជា ចម្លើយរបស់គាត់នៅក្នុងសំណុំរឿងលេខ០០២ដែលស្រង់ដោយ សចស បញ្ជាក់អំពីការប្រព្រឹត្តបទឧក្រិដ្ឋនានា និងអំពីវត្តមាននៃពលទាហានដែលមកពីកំពង់សោមក្តី[59]ក៏គាត់មិនទាន់ត្រូវបានគេធ្វើសម្ភាសន៍នៅក្នុងសំណុំរឿងនេះដែរ។ ឯកសារភស្តុតាងបញ្ជាក់ថា មានការប្រព្រឹត្តឧក្រិដ្ឋកម្មនានាប្រឆាំងនឹងជនជាតិវៀតណាមដោយកងកម្លាំងនៃកងទ័ពបដិវត្តន៍កម្ពុជា ប៉ុន្តែការប្រព្រឹត្តទាំងនេះមានការជាប់ពាក់ព័ន្ធទៅនឹងកងពលធំលេខ១៦៤ត្រឹមកំរិតណានោះ គឺមិនទាន់ឃើញមានការបញ្ជាក់ឲ្យបានច្បាស់តាមរយៈការធ្វើសម្ភាសន៍សាក្សីនានានៅឡើយទេ[60]។

១៨. ការស៊ើបសួរជាដុំកំភួន គឺជាការចាំបាច់ណាស់ដើម្បីបញ្ជាក់ពីការពិតអំពីអង្គហេតុស្តីពីការចូលរួមរបស់កងពលធំលេខ១៦៤នៅក្នុងឧក្រិដ្ឋកម្មទាំងនេះ។ សហព្រះរាជអាជ្ញាអន្តរជាតិ សូមស្នើឲ្យធ្វើសម្ភាសន៍សាក្សីទាំងឡាយដែលបានដឹងច្បាស់ប្រកបដោយសក្តានុពលអំពីឧក្រិដ្ឋម្មទាំងនេះ ដែលរួមទាំងសាក្សីទាំងឡាយដែលបានផ្តល់នូវភស្តុតាងពាក់ព័ន្ធនៅក្នុងសំណុំរឿងលេខ០០២ផងអំពីការចោទប្រកាន់ជាក់លាក់នានាដែលទាក់ទងនឹងសំណុំរឿងលេ០០៣។ ជាអប្បបិមា ការធ្វើសម្ភាសន៍ខាងលើនេះគួរបានរួមបញ្ចូលនូវបុគ្គលទាំងឡាយដែលមានឈ្មោះដូចតទៅនេះ៖ ឡាយ អ៊ាន (LAY Ean), នង សុផាង (NORNG Sophang)[61], អៀង ផន (IENG Phan)[62], ឡុញ ដុស (LONH

---

[57] កំណត់ហេតុស្តាប់ចម្លើយសាក្សីឈ្មោះ ឈូក រិន, ចុះថ្ងៃទី២៤ មីនា ២០១១, ឯកសារលេខ D6។

[58] ចម្លើយរបស់ឈ្មោះ ឡាយ អ៊ាន (Lay Ean) ដែលស្រង់ដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា, ចុះថ្ងៃទី២៧ មិថុនា ២០០៣, ឯកសារលេខ D1.3.32.26 ។

[59] កំណត់ហេតុស្តាប់ចម្លើយរបស់ឈ្មោះ ឡាយ អ៊ាន (Lay Ean), ចុះថ្ងៃទី៤ មីនា២០០៨, និង១៧ មករា ២០០៩, ឯកសារលេខ D4.1.550 និង D4.1.554 ។

[60] *សូមអាន* ឧទាហរណ៍ដូចជា ការប្រាស្រ័យទាក់ទងគ្នារបស់ កម្ពុជាប្រជាធិបតេយ្យ ដែលមាននៅក្នុងឯកសារ D4.1.230, D4.1.606 និង D4.1.214 ។

[61] កំណត់ហេតុស្តាប់ចម្លើយរបស់ឈ្មោះ នង សុផាង (NORNG Sophang), ចុះថ្ងៃទី១៨ កុម្ភៈ ២០០៩, ឯកសារលេខ D4.1.611 ។

[62] កំណត់ហេតុស្តាប់ចម្លើយរបស់ឈ្មោះ អ៊ាង ផាន (IENG Phan), ចុះថ្ងៃទី២៣ វិច្ឆិកា ២០០៩, ឯកសារលេខ D4.1.846 ។

Dos) និង អ៊ុង រ៉េន(UNG Ren)[63], ឃុន គីម *ហៅ* នួន ប៉ែត(KHUM Kim alias NUON Paet)[64], គុង គីម *ហៅ* កែ (KUNG Kim alias Kae)[65], តាន់ សារឿន(TANN Saroeun)[66], និង ជួន ធី *ហៅ* ធី ឪ (CHUON Thi alis THI Ov)[67]។ គួរបានបង្ហាញ ឯកសារភស្តុតាងពាក់ព័ន្ធនានាដល់សាក្សីទាំងនេះ ហើយស្នើឱ្យពួកគេធ្វើការអធិប្បាយផ្តល់មតិលើពីការចូលរួមរបស់កងពលធំលេខ១៦៤នៅក្នុងឧក្រិដ្ឋកម្មទាំងឡាយ ដែលបានរៀបរាប់នៅក្នុងឯកសារភស្តុតាងទាំងនោះ។

## អំពីតួនាទីរបស់ជនសង្ស័យឈ្មោះ មាស មុត

១៩. ទោះបីជាមកទល់ពេលនេះការស៊ើបសួរត្រូវបានធ្វើឡើងក្នុងកំរិតដ៏តិចតួចនោះក៏ដោយ ក៏ភស្តុតាងនៅក្នុងសំណុំរឿងបានចង្អុលបង្ហាញ ឬបញ្ជាក់ថា មាស មុត គឺជាលេខានៃកងពលធំលេខ១៦៤ នៃកងទ័ពបដិវត្តន៍កម្ពុជានៅក្នុងទូទាំងអម្លុងពេលដែលកំពុងស្ថិតនៅក្រោមកិច្ចស៊ើបសួរ, គាត់គឺជាអ្នកដែលមានការបញ្ជាដោយផ្ទាល់ មានសិទ្ធិអំណាច និងការត្រួតត្រាដោយផ្ទាល់ពីលើចារីទាំងឡាយជាអ្នកដែលបានប្រព្រឹត្តផ្ទាល់នូវឧក្រិដ្ឋកម្មនានា ដូចដែលបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ហើយនិងថា គាត់ក៏ជាអ្នកដែលបានចូលរួមដោយខ្លួនគាត់ផ្ទាល់នៅក្នុងឧក្រិដ្ឋកម្មទាំងនោះដែរ ។ ហើយក៏មានភស្តុតាងដែលបង្ហាញផងដែរថា មាស មុត គឺជាសមាជិកម្នាក់នៃអគ្គសេនាធិការនៃកងទ័ពបដិវត្តន៍កម្ពុជា និងជាសមាជិកនៃមជ្ឈិមបក្ស ឬគណៈកម្មាធិការនានាដែលជួយដល់មជ្ឈិមបក្ស និងថា ដោយស្ថិតនៅក្នុងមុខតំណែងជាន់ខ្ពស់ទាំងនេះ គាត់បានចូលរួមយ៉ាងសកម្មនៅក្នុងការបង្កើត និងការអនុវត្តនូវផែនការឧក្រិដ្ឋកម្មរួម[68]។ មុខតំណែងរបស់គាត់ជាមេបញ្ជាការកងទ័ពជើងទឹកនៃកម្ពុជាប្រជាធិបតេយ្យ សមាជិកភាពជាន់ខ្ពស់របស់គាត់នៅក្នុងបកក និងក្នុងស្ថាប័ននានានៃកងទ័ពបដិវត្តន៍កម្ពុជា ហើយនិងទំនាក់ទំនងយ៉ាងជិតស្និទ្ធរបស់គាត់ជា

[63] *សូមអាន* ផ្នែកស្តីពី "តួនាទីរបស់ជនសង្ស័យ មាស មុត"ដូចខាងក្រោមនេះ។

[64] កំណត់ហេតុស្តាប់ចម្លើយរបស់ឈ្មោះ ឃុន គីម *ហៅ* នួន ប៉ែត (KHUM Kim alias NUON Pet), ចុះថ្ងៃទី៣០ មេសា ២០០៨, ឯកសារលេខ D4.1.407 ។

[65] កំណត់ហេតុស្តាប់ចម្លើយរបស់ឈ្មោះ គុង គីម *ហៅ* កែ (KUNG Kim alias Kae), ចុះថ្ងៃទី៩ មករា ២០០៩, ឯកសារលេខ D4.1.556 ។

[66] កំណត់ហេតុស្តាប់ចម្លើយរបស់ឈ្មោះ តាន់ សារឿន(TANN Saroeun), ចុះថ្ងៃទី៣ មិថុនា ២០០៨, ឯកសារលេខ D4.1.458 ។

[67] កំណត់ហេតុស្តាប់ចម្លើយរបស់ឈ្មោះ ជួន ធី *ហៅ* ធី ឪ (CHUON Thi alis THI Ov), ចុះថ្ងៃទី២ មីនា ២០១០, ឯកសារលេខ D4.1.1056។

[68] កំណត់ហេតុស្តាប់ចម្លើយរបស់ឈ្មោះ កាំង ហ្កេកអ៊ាវ *ហៅ* ឌុច, ចុះថ្ងៃទី២៧ មេសា ២០១១, ឯកសារលេខ D12, ត្រង់ទំព័រ៣-៥។ សូមអានផងដែរ កំណត់ហេតុសួរចម្លើយជនត្រូវចោទឈ្មោះ ខៀវ សំផន, ចុះថ្ងៃទី១៣ ធ្នូ ២០០៧, ឯកសារលេខ D46, ត្រង់ទំព័រ១១។ សូមអានផងដែរ ឯកសារភស្តុតាងដែលនៅក្នុងសំណុំរឿង, ដែលរួមមានកំណត់ហេតុអង្គប្រជុំនានា (រួមមាន D1.3.27 និង D1.3.8.3) និងក៏ដូចជាការប្រស្រ័យទាក់ទងគ្នាទៅវិញទៅមកយ៉ាងច្រើនដែលជាភស្តុតាងនៃការចូលរួមរបស់ មាសមុត ក្នុងឧក្រិដ្ឋកម្ម (រួមមាន D4.1.635, D1.3.12.3, D1.3.14.1, D1.3.34.60, D1.3.30.2, D4.1.638-639, D1.3.34.10, D1.3.12.18)។

មួយនឹងសមាជិកនានានៃ គណៈកម្មាធិការអចិន្ត្រៃយ៍នៃ បកក គឺជាភស្តុតាងដែលបង្ហាញយ៉ាងច្បាស់ថា គាត់គឺជាមេដឹកនាំជាន់ខ្ពស់មួយរូបនៃកម្ពុជាប្រជាធិបតេយ្យ ។ កំរិតនៃឧក្រិដ្ឋកម្មនានាដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តដោយពួកអ្នកដែលស្ថិតនៅក្រោមបញ្ជារបស់គាត់, ចំនួនដ៏ច្រើនសន្ធឹកសន្ធាប់នៃជនរងគ្រោះ, អម្លុងពេលដែលឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្ត និងទំហំដ៏ធំទូលាយនៃភូមិសាស្ត្រដែលក្នុងនោះឧក្រិដ្ឋកម្មនានាបានកើតឡើង ក៏សុទ្ធតែបញ្ជាក់យ៉ាងច្បាស់ផងដែរថា មាស មុត គឺជាអ្នកទទួលខុសខ្ពស់បំផុតមួយរូបចំពោះឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។

២០. នៅពេលដែលឯកសារភស្តុតាងបរិមាណ(ចំនួន)ដ៏ធំគួរឲ្យកត់សំគាល់ត្រូវបានគេដាក់បញ្ចូលទៅក្នុងសំណុំរឿងហើយនោះ ការស៊ើបសួរមិនទាន់ចប់សព្វគ្រប់នៅឡើយទេ ដោយសារតែតួនាទីរបស់ មាស មុត នៅក្នុងឧក្រិដ្ឋកម្មទាំងនោះ មិនទាន់ត្រូវបានធ្វើការស៊ើបសួរពេញលេញ ឬទាំងស្រុងនៅឡើយ។ គឺមានសាក្សីតែពីររូបប៉ុណ្ណោះ ដែលក្នុងនោះមានម្នាក់បានដឹងតិចតួចអំពីសកម្មភាពរបស់ មាស មុត នៅក្នុងអម្លុងនៃរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានគេធ្វើសម្ភាសន៍អំពីបញ្ជាសិទ្ធិអំណាចបុគ្គលនិងការចូលរួមដោយផ្ទាល់របស់ មាស មុត នៅក្នុងឧក្រិដ្ឋកម្មទាំងនោះ[69]។ ការធ្វើសម្ភាសន៍ឈ្មោះ កាំង ហ្គេកអ៊ាវ *ហៅ* ឌុច មិនទាន់បានពេញលេញទេ ដោយសារតែបញ្ហាជាច្រើនដែលត្រូវដាក់ទៅឲ្យ ឌុច មិនត្រូវបានគេលើកឡើងទេនៅក្នុងពេលធ្វើសម្ភាសន៍នោះ[70]។ សហព្រះរាជអាជ្ញាអន្តរជាតិ ក៏កត់សំគាល់ផងដែរថា ទោះបីជាគាត់ជាជនសង្ស័យមួយរូបដែលមានជាប់ពាក់ព័ន្ធនៅក្នុងចម្លើយសាក្សីនិងក្នុងឯកសារភស្តុតាងក៏ដោយក៏ មាស មុត មិនទាន់ត្រូវបានធ្វើសម្ភាសន៍ ឬ ត្រូវគេប្រាប់ឲ្យដឹងថា រូបគាត់កំពុងតែស្ថិតនៅក្នុងកិច្ចស៊ើបសួរឡើយ។

២១. សហព្រះរាជអាជ្ញាអន្តរជាតិ សូមស្នើឲ្យការបំពេញកិច្ចស៊ើបសួរជាក់លាក់ដូចរៀបរាប់ខាងក្រោមនេះត្រូវបានធ្វើឡើងដើម្បីបញ្ជាក់ពីការពិតចំពោះការចោទប្រកាន់ទាំងឡាយដូចដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដែលរួមមានលើអង្គហេតុដូចខាងក្រោម៖

(ក) អំពីតួនាទីរបស់ មាស មុត នៅក្នុង បកក មុនឆ្នាំ១៩៧៥ ការតែងតាំងគាត់ជាលេខានៃកងពលធំលេខ៣/១៦៤ និងការបញ្ជា សិទ្ធិអំណាច និងការត្រួតត្រារបស់គាត់ទៅលើកងពលធំនេះនៅក្នុងទូទាំងអម្លុងពេលដែលស្ថិតនៅក្រោមកិច្ចស៊ើបសួរ។

(ខ) អំពីសមាជិកភាពនៅក្នុងគណៈកម្មាធិការមជ្ឈិមបក្ស បកក ឬនៅក្នុងស្ថាប័នជំនួយនៃគណៈកម្មាធិការមជ្ឈិមបក្ស និងនៅក្នុងអគ្គសេនាធិការកងទ័ពបដិវត្តន៍កម្ពុជា របស់ មាស មុត និងការចូលរួមរបស់គាត់នៅក្នុងកិច្ចប្រជុំនានារបស់ស្ថាប័នទាំងនេះ ក៏ដូចជានៅក្នុង

[69] កំណត់ហេតុស្ដាប់ចម្លើយសាក្សីឈ្មោះ ឈូក រិន, ចុះថ្ងៃទី២៤ មីនា ២០១១, ឯកសារលេខ D6។ កំណត់ហេតុស្ដាប់ចម្លើយរបស់ឈ្មោះ កាំង ហ្គេកអ៊ាវ *ហៅ*ឌុច, ចុះថ្ងៃទី២៧ មេសា ២០១១, ឯកសារលេខ D12។

[70] សូមអាន បញ្ជីរាយអំពីបញ្ហានានាដែលត្រូវសាកសួរ ឌុច បន្ថែមទៀត ដូចខាងក្រោម។

ការប្រជុំផ្សេងៗទៀត (ដូចជា ការប្រជុំជាមួយ ប៉ុល ពត) ដែលនៅក្នុងអង្គប្រជុំទាំងនោះ ឧក្រិដ្ឋកម្មនានាត្រូវបានរៀបចំផែនការ ពិភាក្សា និងសម្របសម្រួល។

(គ) អំពីការចូលរួមរបស់ មាស មុត នៅក្នុងឧក្រិដ្ឋកម្មផ្សេងៗ ដែលរួមមាន៖ (១) ការបញ្ជា ត្រួតត្រា និងត្រួតមើលពីលើពួកអ្នកដែលជាចារីផ្ទាល់នៃឧក្រិដ្ឋកម្មនានាដែលនៅក្នុង និង នៅជុំវិញកំពង់សោម និងនៅតាមបណ្តាកោះទាំងឡាយដែលស្ថិតនៅក្រៅពីឆ្នេរសមុទ្រកម្ពុជា, នៅមន្ទីរសន្តិសុខវត្តឥន្ទញាណ, កន្លែងយកថ្មនៅស្ទឹងហាវ, និងនៅក្នុងទីកដីវៀតណាម។ (២) សកម្មភាពនានារបស់គាត់នៅក្នុងតំបន់៥០៥ ក្នុងអំឡុងឆ្នាំ១៩៧៨។ (៣) ការឲ្យបញ្ជា និងការអនុញ្ញាតក្នុងការចាប់ខ្លួនការដាក់នៅក្នុងមន្ទីរឃុំឃាំងដោយខុសច្បាប់ ការធ្វើទារុណកម្ម និងការសម្លាប់ខ្មាំងនិងជនជាតិបរទេស ក៏ដូចជាការប្រើប្រាស់ការធ្វើពលកម្មដោយបង្ខំ ហើយនិងអំពើអមនុស្សធម៌ផ្សេងៗទៀត។ (៤) ការអនុញ្ញាតរបស់គាត់ ក្នុងការផ្ទេរពួកអ្នកទោសទៅកាន់មន្ទីរស-២១ ការទទួលរបស់គាត់នូវចម្លើយសារភាពនានាមកពីមន្ទីរស២១ និងការចូលរួមរបស់គាត់នៅក្នុងការចាប់ខ្លួនពួកអ្នកដែលគេសន្មត់ថា ជាខ្មាំងដែលត្រូវបានគេផ្តល់អត្តញ្ញាណឲ្យនៅក្នុងចម្លើយសារភាពទាំងនោះ។ (៥) ការដឹងរបស់គាត់អំពីក្រិដ្ឋកម្មតាមរយៈការចូលរួមរបស់គាត់នៅទីតាំងឧក្រិដ្ឋកម្មនានា ការទទួលរបាយការណ៍ និងការធ្វើអន្តរសម្មភាពជាមួយចារីនានាដូចជា ឌុច និងកម្មាភិបាលនានានៅក្នុងវរៈសេនាតូច៤៥០ របស់កងពលធំលើខ១៦៤។ និង (៦) ការចូលរួមរបស់គាត់នៅក្នុងការបំពាក់ទ្រឹស្តីនយោបាយដល់កម្មាភិបាលនានា។

(គ) រចនាសម្ព័ន្ធសិទ្ធិអំណាច ឋានានុក្រម និងខ្សែរយៈបញ្ជានៅក្នុងរង្វង់កងពលធំលេខ១៦៤ ដែលរួមមាន៖ កងវរៈសេនាធំលេខ២០(១៦១), ២១(១៦២), ២២(១៦៣), និង ១៤០។ កងវរៈសេនាតូចលេខ៣៨៦, ៤៥០, ១៦៥, ១៦៦, ១៧៦, ១៦៨, ១៦៩, ១៧០, ៥២០(១៤១), ៥៣០(១៤២), ៥៤០(១៤៣) និង៥៥០(១៤៤)។ និងបណ្តាអង្គភាពថ្នាក់ក្រោមទាំងឡាយដូចជា អង្គភាពនាវាប្រដេញ អង្គភាពការពារ អង្គភាពប្រឆាំងនឹងនាវាមុជទឹក និងអង្គភាពដែលបានរៀបរាប់ដោយសាក្សីនានាថា ជាអង្គភាពដែលទទួលខុសត្រូវចំពោះការចាប់ខ្លួន ដែលប្រើប្រាស់អក្សរកាត់ថា នាវា (PCS) ឬ (PCF)[71]។

២២. ការស៊ើបសួរជាក់លាក់មួយចំនួនដែលបានស្នើសុំដោយសហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធនឹង មាស មុត គឺមានដូចតទៅ៖

(ក) ស្តាប់ចម្លើយ ឌុច សារជាថ្មី និង សួរសំនួរបន្ថែមទៀតទៅកាន់គាត់ ពាក់ព័ន្ធនឹងការចូលរួមចំណែករបស់ មាស មុត នៅក្នុងឧក្រិដ្ឋកម្មនានា រួមមាន៖

[71] កំណត់ហេតុស្តាប់ចម្លើយសាក្សីឈ្មោះ ទូច សឿលី, ចុះថ្ងៃទី១០ វិច្ឆិកា ២០១០, ឯកសារលេខ D2/15, ត្រង់ទំព័រ៤។

(i) តើពួកអ្នកទោសត្រូវបានបញ្ជូនពីកំពង់សោមទៅស-២១ យ៉ាងដូចម្ដេច និងដោយនរណា, តើ មាស មុត បានចេញបញ្ជាឲ្យមានការចាប់ និងបញ្ជូនខ្លួនទាំងនោះដែរឬទេ, ហើយថាបើពុំនោះសោតទេតើគាត់បានចូលរួមចំណែកនៅក្នុងនោះ ឬបានដឹងពីរឿងទាំងនោះដែរឬទេ ។ សហព្រះរាជអាជ្ញាអន្តរជាតិកត់សម្គាល់ថា នៅក្នុងសំណុំរឿងលេខ ០០២ ឌុច បានថ្លែងថា៖ "ខ្ញុំ ដឹងថាគឺកងពលលេខ១៦៤ ដែលដឹកនាំដោយ មាស មុត ជាអ្នកចាប់ខ្លួន[ជនបរទេសបួន(០៤)នាក់]..."[72] ។

(ii) តើ មាស មុត បានធ្វើការប្រាស្រ័យទាក់ទងជាមួយនឹង ឌុច តាមរបៀបណា, តើចម្លើយសារភាពនានាដែលបានមកពីពួកអ្នកទោសនៅមន្ទីរស-២១ ត្រូវបានផ្ដល់ឲ្យទៅ មាស មុត (ឬបើពុំនោះសោតទេ ខ្លឹមសារនៃចម្លើយសារភាពទាំងនោះត្រូវបានរាយការណ៍ទៅឲ្យគាត់) ដែរឬទេ និង តើគាត់បានចាត់ការដើម្បីស៊ើបអង្កេត ឬចាប់ខ្លួនពួកខ្មាំងក្រោយទៀត ដែលត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងចម្លើយសារភាពទាំងនោះ ដែរឬទេ ។ ដោយឡែក៖

**(ក)** ឌុច គួរតែត្រូវបានបង្ហាញពីចម្លើយសារភាពរបស់ឈ្មោះ គង់ គៀន *ហៅ* អ៊ឹង វ៉េត ជាបញ្ជាការកងវរសេនាតូច នៅក្នុង កងពលធំលេខ ១៦៤[73] ។ ផងដែរ សចស គួរតែប្រមូលដកច្បាប់ចម្លងទាំងស្រុងនៃគ្រប់ចម្លើយសារភាពទាំងអស់នៅមន្ទីរស-២១ របស់ពួកអតីតកម្មាភិបាល ដែលមកពីអង្គភាពនានានៅក្នុងកងពលធំលេខ ១៦៤, ពិនិត្យចម្លើយសារភាពទាំងនោះសារជាថ្មីឡើងវិញ តើមានចំណារអ្វីដែលយោងទៅដល់ឈ្មោះ មាស មុត ដែរឬទេ ហើយនិងសួរ ឌុច ឲ្យធ្វើសេចក្ដីអត្ថាធិប្បាយលើចំណារទាំងនោះ ។

**(ខ)** ឌុច គួរតែត្រូវបានសួរអំពីការចាប់ខ្លួនរបស់ពួកកម្មាភិបាលជាន់ខ្ពស់នៃកងពលធំលេខ ១៦៤ ដែលបានកំណត់អត្តសញ្ញាណនៅក្នុងឯកសារលេខ D9.3 រួមមានឈ្មោះ ហ៊ឹង ឌឿន *ហៅ* ឌឹម (HOENG Doeun *alias* Dim) ជាអនុលេខាកងពលធំ និង គុន ឌឹម (KUN Dim) ជាបញ្ជាការកងវរសេនាតូចលេខ ១៤១[74] ។

---

[72] សំណុំរឿងលេខ ០០២, កំណត់ហេតុសួរចម្លើយឈ្មោះ កាំង ហ្កេកអ៊ាវ ហៅ ឌុច, ថ្ងៃទី២៤ មិថុនា ២០០៨, D89, ត្រង់ទំព័រទី ៥ ។

[73] ចម្លើយសារភាពនៅស-២១ របស់ គង់ គៀន *ហៅ* អ៊ឹង វ៉េត (លេខាកងវរសេនាតូចលេខ ៦៣១, កងវរ សេនាធំលេខ ៦៣, កងពលធំលេខ ១៦៤), ថ្ងៃទី២៦ ឧសភា ១៩៧៧, D1.3.18.4 (ចម្លើយសារភាពមានចំណាររបស់ នួន ជា ដូចតទៅ៖ *"មនុស្សភាគច្រើន ទ/ទ ខាង ស/ម មុត"*) ។ *សូមមើល* សុំណុំរឿងលេខ ០០២, ឯកសារ D225, ត្រង់ទំព័រទី ៤ - ចម្លើយសារភាពនេះគួរត្រូវបានផ្ទេរចូលទៅក្នុងសំណុំរឿងលេខ ០០៣) ។ តារាងឈ្មោះអ្នកទោសរបស់ សចស មកពីកងពលធំលេខ ១៦៤ បានកំណត់អត្តសញ្ញាណបុគ្គលនេះថាជា បញ្ជាការកងវរសេនាតូចលេខ ១៦៥, ឬ កងវរសេនាធំលេខ ៦៣ (D1.3.11.3) ។

[74] បញ្ជីឈ្មោះអ្នកត្រូវចាប់ខ្លួនមកពីកងពលធំលេខ ១៦៤, ថ្ងៃទី២៥ មករា ២០០៨, D9.3 ។

(iii) បរិយាយឱ្យបានល្អិតល្អន់ពីចម្លើយរបស់គាត់ដូចតទៅនេះ ដែលបានធ្វើឡើងនៅក្នុងបទសម្ភាសន៍មួយ ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១១៖ "ហើយ សុន សេន មុនពេលសម្រេច គាត់តែងតែសុំយោបល់ និងការជួយសម្រេចពីប្រធានកងពលផ្ទាល់នោះ"[75] ។ ជាពិសេស គាត់គួរតែត្រូវបានសួរឱ្យធ្វើការពន្យល់អំពីថា តើការណ៍នេះមានពាក់ព័ន្ធយ៉ាងដូចម្ដេចទៅនឹងការចូលរួមចំណែករបស់ មាស មុត នៅក្នុងការបោសសម្អាតនានា និងការងាររបស់អគ្គសេនាធិការនៃកងទ័ពបដិវត្តកម្ពុជា ។

(iv) រៀបរាប់គ្រប់ការប្រជុំទាំងអស់ (រួមមាន ការប្រជុំនានារបស់អគ្គសេនាធិការនៃកងទ័ពបដិវត្តកម្ពុជា និងវគ្គរៀនសូត្រនានា) ដែលគាត់បានចូលរួម, ដែលនៅក្នុងការប្រជុំទាំងនោះ មាស មុត ក៏មានវត្តមានផងដែរ ។

(v) រកឈ្មោះពួកកម្មាភិបាលដែលនៅរស់រានមានជីវិតដទៃទៀតរូបណាក៏ដោយ ដែលធ្លាប់បានដឹងពីមុខតំណែង និងសកម្មភាពនានារបស់ មាស មុត ក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរនេះ ។

(ខ) ស្ដាប់ចម្លើយសារជាថ្មីឡើងវិញលើសាក្សីនានា ដែលអាចមានលទ្ធភាពនឹងផ្ដល់សក្ខីកម្មបន្ថែមទៀតពីមុខតំណែង សិទ្ធិអំណាច និង ការចូលរួមប្រព្រឹត្តឧក្រិដ្ឋកម្មនានារបស់ឈ្មោះ មាស មុត នៅកំពង់សោម រួមមានឈ្មោះ៖ សយ ប៊ន និង ទូច សឿលី (ទាំងពីរនាក់នេះបានបញ្ជាក់ថាពួកគេបានចូលរួមនៅក្នុងវគ្គបណ្ដុះបណ្ដាលនានាជាមួយនឹងឈ្មោះ មាស មុត)[76] ។

(គ) ស្ដាប់ចម្លើយសារជាថ្មីឡើងវិញលើសាក្សីនានានៅក្នុងសំណុំរឿងលេខ ០០២ ដែលមានឈ្មោះដូចតទៅ៖ ទី១) ឡុញ ដុស ពាក់ព័ន្ធនឹងសមាជិកភាពរបស់ឈ្មោះ មាស មុត នៅក្នុងអគ្គសេនាធិការនៃកងទ័ពបដិវត្តកម្ពុជា វត្តមាននៅក្នុងការប្រជុំកងទ័ពបដិវត្តកម្ពុជា និងការចូលរួមនៅក្នុងការបោសសម្អាតផ្ទៃក្នុង[77], ទី២) អ៊ឹង រ៉ែន ពាក់ព័ន្ធនឹងសិទ្ធិអំណាចរបស់ឈ្មោះ មាស មុត ក្នុងឋានៈជាបញ្ជាការកងពលធំ និងសមាជិកភាពរបស់គាត់នៅក្នុងអគ្គសេនាធិការនៃកងទ័ពបដិវត្តកម្ពុជា និងវត្តមានរបស់គាត់នៅក្នុងការប្រជុំ និងក្នុងវគ្គបណ្ដុះបណ្ដាលនានានៃអគ្គសេនាធិការ[78], និងទី៣)

---

[75] កំណត់ហេតុសួរចម្លើយឈ្មោះ កាំង ហ្កេកអ៊ាវ *ហៅ*ឌុច, ថ្ងៃទី២៧ មេសា ២០១១, D12, ត្រង់ទំព័រទី ៥ ។

[76] កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សយ ប៊ន, ថ្ងៃទី៦ កញ្ញា ២០១០, D2/8, ត្រង់ទំព័រទី ៥ ។ បទសម្ភាសន៍របស់ កសព ជាមួយ ទូច សឿលី, ថ្ងៃទី១៦ សីហា ២០០៨, D1.3.13.13, ត្រង់ទំព័រទី ៦ ។

[77] កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឡុញ ដុស, ថ្ងៃទី២៣ កក្កដា ២០០៩, D4.1.855 ។

[78] កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អ៊ឹង រ៉ែន, ថ្ងៃទី១៧ កញ្ញា ២០០៩, D232/21 ។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អ៊ឹង រ៉ែន, ថ្ងៃទី២៦ តុលា ២០០៩, D232/36 ។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អ៊ឹង រ៉ែន, ថ្ងៃទី៤ មីនា ២០១០, D369/11 ។

សេង សឿន ទាក់ទងទៅនឹងការចូលរួមចំណែក របស់ឈ្មោះ មាស មុត នៅក្នុងការបោសសម្អាតនានាលើពួកកម្មភិបាលភូមិភាគបូព៌ា ក្នុងតំបន់ ៥០៥ ព្រមទាំងសិទ្ធិអំណាចរបស់គាត់នៅក្នុងតំបន់នោះ[79] ។

(ឃ) ស្តាប់ចម្លើយអ្នកដាក់ពាក្យបណ្តឹងសុំធ្វើជាដើមរដ្ឋប្បវេណីឈ្មោះ រ៉ុប ហាមីល ពាក់ព័ន្ធនឹងលទ្ធផលនៃការសាកសួរនានានៅក្នុងការចាប់ខ្លួនបងប្រុសរបស់គាត់ ឈ្មោះ ឃែរី ហាមីល ហើយដោយឡែក ថាតើការបញ្ជូនទៅកាន់មន្ទីរស-២១ ត្រូវបានអនុញ្ញាត ឬត្រូវបានបញ្ជាដោយឈ្មោះ មាស មុត ដែរឬយ៉ាងណា ។

(ង) កំណត់ទីកន្លែង និងស្តាប់ចម្លើយពួកកម្មាភិបាលជាន់ខ្ពស់នៃកងពលធំលេខ ១៦៤ ដែលនៅក្នុងផ្នែកនានាខាងលើ រួមមាន៖ ស សាមឿន (*ហៅ* តាមឿន)[80], តា នន[81], នង ឆាន / សួន ឆាន / ណន ឆាន[82], ហន / ហុន[83], តា ង៉ែត[84], មាញ[85], តា យ៉ាន, ស្រស់ និង ញ៉ាន់[86] ។

(ច) សួរចម្លើយពួកជនជាប់ចោទទាំងបួននាក់នៅក្នុងសំណុំរឿងលេខ 00២ (នួន ជា, អៀង សារី, ខៀវ សំផន និង អៀង ធីរិទ្ធ) ពាក់ព័ន្ធនឹងតួនាទី និងសិទ្ធិអំណាចរបស់ឈ្មោះ មាស មុត រួមមានសមាជិកភាពរបស់គាត់នៅក្នុងគណៈមជ្ឈិម ឬក្នុងគណៈជំនួយការរបស់វា (its Assisting Committee) និងនៅក្នុងអគ្គសេនាធិការនៃកងទ័ពបដិវត្តកម្ពុជា ។

---

[79] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន, ថ្ងៃទី១១ វិច្ឆិកា ២០០៩, D232/59 ។

[80] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូច សឿលី, ថ្ងៃទី១០ វិច្ឆិកា ២០១០, D2/15, ត្រង់ទំព័រទី ៥-៨ ។ ស សាមឿន ត្រូវបានគេរាយការណ៍មកថាបានរស់នៅឯវត្តឥន្ទ្របញ្ញាណជាមួយសាក្សីរូបនោះចាប់ពីខែសីហា ១៩៧៥ ។

[81] ដូចខាងលើ, ត្រង់ទំព័រទី ៨ ។ នន ត្រូវបានគេរាយការណ៍មកថាត្រូវបានចាប់ខ្លួនក្នុងឆ្នាំ ១៩៧៧/៧៨ ដោយសាររំលោភសេពសន្ថវៈលើអ្នកទោសនារីម្នាក់ ប៉ុន្តែអ្វីដែលគាត់រស់នៅក្រោយមកទៀតមិនត្រូវបានគេដឹងច្បាស់លាស់ទេ។ របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង, ថ្ងៃទី២៩ ធ្នូ ២០១០, D2/22, ត្រង់ទំព័រទី ៦ ។

[82] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូច សឿលី, ថ្ងៃទី១១ វិច្ឆិកា ២០១០, D2/16, ត្រង់ទំព័រទី ៤ ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ែន សារិន, ថ្ងៃទី២៦ សីហា ២០១០, D2/7, ត្រង់ទំព័រទី ៣ ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សយ ប៊ិន, ថ្ងៃទី៧ កញ្ញា ២០១០, D2/9, ត្រង់ទំព័រទី ៦ ។

[83] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សយ ប៊ិន, ថ្ងៃទី៧ កញ្ញា ២០១០, D2/9, ត្រង់ទំព័រទី ៦ ។ បទសម្ភាសន៍របស់ កសព ជាមួយ ទូច សឿលី, ថ្ងៃទី១៦ សីហា ២០០៨, D1.3.13.13, ត្រង់ទំព័រទី ៤, ៦ ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញូង ជ្រោង, ថ្ងៃទី២៤ សីហា ២០១០, D2/6, ត្រង់ទំព័រទី ៥ ។

[84] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សយ ប៊ិន, ថ្ងៃទី៦ កញ្ញា ២០១០, D2/8, ត្រង់ទំព័រទី ៧ ។

[85] ដូចខាងលើ, ត្រង់ទំព័រទី ៨ ។

[86] ដូចខាងលើ, ត្រង់ទំព័រទី ៧ ។ បទសម្ភាសន៍របស់ កសព ជាមួយ ទូច សឿលី, ថ្ងៃទី១៦ សីហា ២០០៨, D1.3.13.13, ត្រង់ទំព័រទី ៦ ។

(ឆ) កោះហៅឈ្មោះ មាស មុត, ជូនដំណឹងដល់គាត់ថាគាត់ឋិតនៅក្រោមការស៊ើបសួរ, ផ្ដល់ប្រឹក្សាពីសិទ្ធិនានាដល់គាត់, និង ផ្ដល់កាលានុវត្តភាពដល់គាត់ឲ្យឆ្លើយនូវសំនួរនានា និងផ្ដល់ភស្តុតាងពាក់ព័ន្ធព័ន្ធនឹងគ្រប់បញ្ហាទាំងអស់ដែលបានរៀបរាប់នៅខាងលើ និងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ[87] ។

## សេចក្ដីសន្និដ្ឋាន

២៣. សហចៅក្រមអន្តរជាតិ សូមស្នើឲ្យ សចសៈ

(ក) ចាត់ធ្វើការស៊ើបសួរលើគ្រប់សំណើសុំដែលបានរៀរាប់នៅខាងលើ ។

(ខ) យល់ឃើញថាចាំបាច់ បំពេញគ្រប់សកម្មភាពបន្ថែមដែលជាលទ្ធផលលេចចេញមកពីការស៊ើបសួរទាំងនោះ ។

(គ) ដាក់ឯកសារជាផ្នែកនៃការស៊ើបសួរដែលប្រមូលបានទាំងនោះ ចូលទៅក្នុងសំណុំរឿងឲ្យបានឆាប់នៅពេលដែលខ្លួនបានទទួល ៕

សូមគោរពដាក់ជូន

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១១ | លោក Andrew CAYLEY សហព្រះរាជអាជ្ញាអន្តរជាតិ | ភ្នំពេញ | |

[87] សហព្រះរាជអាជ្ញាអន្តរជាតិកត់សម្គាល់ថា ក្នុងការឆ្លើយតបទៅនឹងការស្ទង់មើលពីបញ្ហានានា ដែលឋិតនៅក្រោមការស៊ើបអង្កេតនៅក្នុងករណីនេះ មាស មុត បានធ្វើអត្ថាធិប្បាយក្នុងពេលថ្មីៗនេះថា គាត់នឹងមានលទ្ធភាពអាចផ្ដល់ព័ត៌មានពាក់ព័ន្ធនឹង "ការវាយប្រយុទ្ធ និងការបាញ់បោះ" (fighting and shooting), James O'TOOLE និង ថេត សម្បត្តិ "អតីតមេខ្មែរក្រហមឆ្លើយតបទៅនឹងការលើកឡើងចោទប្រកាន់របស់ពួកសកម្មជន", កាសែតភ្នំពេញប៉ុស្ដិ៍, ថ្ងៃទី៦ មេសា ២០១១ (ឯកសារត្រូវបានដាក់ជូនដោយសហព្រះរាជអាជ្ញាអន្តរជាតិ) ។